ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ
# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# ២០១៤ - ២០១៨

## ១. វឌ្ឍនភាពដែលសម្រេចបាន ឆ្នាំ ២០១៦



ខែ ធ្នូ ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# ការវាយតម្លៃពាក់កណ្ដាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ
# យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# ២០១៤ - ២០១៨

## ១. វឌ្ឍនភាពដែលសម្រេចបាន ឆ្នាំ ២០១៦



ខែ ធ្នូ  ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........................................................................................ ១

អក្សរកាត់ និងពាក្យកាត់ ........................................................................................ ៣

សេចក្តីផ្តើម ........................................................................................................ ៤

របាយការណ៍សង្ខេបនៃការវាយតម្លៃពាក់កណ្តាលអាណត្តិត្រឹមឆ្នាំ២០១៦ ................................ ៦

អាទិភាពទី ១៖ ភាពមានស្បៀង និងការទទួលបានស្បៀងប្រកបដោយនិរន្តរភាព នៅកម្រិតគ្រួសារ ..... ៩

អាទិភាពទី ២៖ ការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ម្ហូបអាហារ សម្រាប់កុមារ និងមាតា ដោយផ្តោតការយកចិត្តទុកដាក់លើរយៈពេល ១.០០០ ថ្ងៃដំបូងនៃជីវិត .................................................. ១១

អាទិភាពទី ៣៖ លើកកម្ពស់ការគាំពារសង្គមទាក់ទីងនឹងសន្តិសុខស្បៀង និងបង្កើនសមត្ថភាពរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដើម្បីទប់ទល់នឹងហានិភ័យ និងវិបត្តិ ដើម្បីបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់អាហាររបស់ពួកគេ ........................................................................................ ១៧

ចំណុចខ្វះខាត និងបញ្ហាប្រឈម .................................................................................. ២០

អនុសាសន៍សំខាន់ៗ ................................................................................................ ២២

ប្រភពព័ត៌មាន ...................................................................................................... ២៥

បញ្ជីឯកសារយោង .................................................................................................. ២៧

# សេចក្តីថ្លែងអំណរគុណ

ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និងជាប្រធានក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសេចក្តីសោមនស្សរីករាយសូមប្រកាសផ្សព្វផ្សាយលទ្ធផលរកឃើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ លើ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០១៤-២០១៨។ ឯកឧត្តមសូមថ្លែងអំណរគុណ ចំពោះការរួមចំណែកដ៏មានសារៈសំខាន់ និងការចូលរួមដ៏សកម្ម ពីមន្ត្រីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ តំណាងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ស្តីពី ការវាយតម្លៃពាក់កណ្តាលអាណត្តិលើ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនេះ។ បន្ថែមលើសពីនេះ ឯកឧត្តម **យឹម ឆៃលី** សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ដែលបានជួយគ្រប់បែបយ៉ាងដល់ការវាយតម្លៃនេះ ដោយមានការចូលរួមពីសហភាពអឺរ៉ុប ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ទីភ្នាក់ងារសហប្រជាជាតិនានា ដូចជាអង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) អង្គការស្បៀងអាហារពិភពលោក (WFP) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ព្រមទាំងសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ ដែលដឹកនាំដោយ អង្គការហេលិន ខេល័រ អន្តរជាតិ (Helen Keller International)។ ឯកឧត្តមក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះធនាគារពិភពលោក ដែលបានជួយធ្វើការពិនិត្យល្អិតល្អន់លើការងារនេះ។

ការងាររបស់គណៈកម្មាធិការផ្តល់ប្រឹក្សា ដែលត្រូវបានបង្កើតឡើងជាផ្លូវការ សម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្តយុទ្ធសាស្ត្រនេះ ហើយដែលមានឯកឧត្តម **ឌី ច័ន្ទផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធាន និងសមាជិកជាតំណាងមកពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងការតម្រង់ទិសដល់ដំណើរការក៏ដូចជាការបញ្ជាក់ផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យឡើងវិញនេះផងដែរ។ ឯកឧត្តមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោកស្រី **Veena Reddy** នាយកបេសកកម្មស្តីទីរបស់ USAID ដែលបានចូលរួមសហការប្រកបដោយការប្តេជ្ញាចិត្តខ្ពស់។ សមាជិកដែលមាននៅក្នុងក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានចូលរួមនៅក្នុងការវាយតម្លៃពាក់កណ្តាលអណត្តិនេះ ហើយឯកឧត្តមសូមធ្វើការវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងគាំទ្ររបស់ពួកគេក្នុងការជម្នះបញ្ហាប្រឈម ដែលកំពុងបន្តកើតមានឡើងក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ជាវេទិកាដ៏សំខាន់ សម្រាប់ធ្វើការផ្សព្វផ្សាយវឌ្ឍនភាព ដែលសម្រេចបានជាមួយនឹងការវាយតម្លៃនេះ ហើយក៏ជាវេទិកាសម្រាប់ការពិភាក្សាពីលទ្ធផលនានាផងដែរ។

បន្ទាប់ពីមានការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញយ៉ាងទូលំទូលាយរួចមក ឯកសារចុងក្រោយត្រូវបានប្រកាសផ្សព្វផ្សាយដោយឯកឧត្តម **យឹម ឆៃលី** ក្នុងនាមតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា លោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោក **David Kaatrud** ប្រធានការិយាល័យតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការស្បៀងអាហារពិភពលោក នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៨។ ឯកសារផ្សេងគ្នាចំនួនបីត្រូវបានរៀបចំឡើងសម្រាប់ការវាយតម្លៃពាក់កណ្តាលអណត្តិនេះ ដោយបានបញ្ចូលគំនិតយោបល់ជាធាតុចូលពីប្រភពផ្សេងៗ

ហើយពង្រាងឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យពិភាក្សាយ៉ាងទូលំទូលាយ។ ឯកសារទាំងបីនេះ ត្រូវបានរៀបចំឡើង ផ្អែកទៅតាមឯកសារយោងជាច្រើន និងការវិភាគមួយចំនួនដែលកំពុងបន្តធ្វើ។ ឯកសារបីសំខាន់ៗនៃការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ រួមមាន៖

១. វឌ្ឍនភាពដែលសម្រេចបានត្រឹមឆ្នាំ ២០១៦

២. ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧

៣. ទិសដៅជាយុទ្ធសាស្ត្រ ឆ្ពោះទៅឆ្នាំ ២០៣០

ខណៈពេលដែលឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយជាមួយគ្នា ឯកសារទាំងនេះជាឯកសារដោយឡែកៗពីគ្នា ដោយហេតុថា ឯកសារនីមួយៗ គឺជាការវិភាគដោយឡែកៗពីគ្នា។ ដូចដែលបង្ហាញនៅក្នុងឯកសារទាំងនេះ ការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ បានផ្តល់នូវរបកគំហើញសំខាន់ៗជាច្រើន ព្រមទាំងផ្តល់នូវការណែនាំអំពីជំហានបន្ទាប់ផងដែរ។ ការវាយតម្លៃនេះក៏ជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ ២០១៩-២០២៣ និងជាមូលដ្ឋានជួយជំរុញកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភផងដែរ។

ដំណើរការពិគ្រោះយោបល់ និងការពិភាក្សានេះ ក៏ជាច្រកសំខាន់សម្រាប់ជួយឱ្យមានការរៀនសូត្រ និងការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ គិតត្រឹមចុងឆ្នាំ២០១៦ មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងការឈានទៅសម្រេចគោលបំណងជាយុទ្ធសាស្ត្រនានា។ ទិសដៅរបស់យើងក្នុងដំណើរផ្លូវឆ្ពោះទៅមុខ ត្រូវបានដាក់ចេញយ៉ាងជាក់ច្បាស់។ យុទ្ធសាស្ត្រនេះជួយតម្រង់ទិសសកម្មភាពដែលត្រូវអនុវត្តសម្រាប់រយៈពេលនៅសេសសល់ រហូតដល់ចុងឆ្នាំ ២០១៨។ គ្រប់គោលនយោបាយ និងកម្មវិធីតាមវិស័យទាំងអស់ គួរបញ្ចូលទិសដៅទាំងនេះ ហើយគោលនយោបាយ និងកម្មវិធីនីមួយៗសុទ្ធតែរួមចំណែកដល់ការសម្រេចទិសដៅទាំងនេះ ទៅតាមតួនាទី និងការទទួលខុសត្រូវរបស់វិស័យនីមួយៗ។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការពង្រឹងយន្តការសម្របសម្រួលការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ ជាពិសេស សំដៅធានាយ៉ាងណាឱ្យមានការកសាងសមត្ថភាព ពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាព នៅចុងរយៈពេលនៃយុទ្ធសាស្ត្រនេះ។ យើងត្រូវធានាយ៉ាងណាឱ្យគ្រប់ភាគីទាំងអស់ធ្វើការងាររួមគ្នា និងត្រូវបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់ភាពអត់ឃ្លាននៅកម្ពុជាឱ្យបានត្រឹមឆ្នាំ ២០៣០។ យើងទាំងអស់គ្នាអាចបង្ហាញពីគំរូភាពដល់ប្រទេសនានា នៅក្នុងសកលលោកទាំងមូល តាមរយៈការខិតខំធ្វើការងារឆ្ពោះទៅសម្រេចគោលដៅនេះ ពោលគឺការធ្វើការងាររួមគ្នាជាធ្លុងមួយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមតម្រាយផ្លូវនៃយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ដទៃទៀត។

# អក្សរកាត់ និងពាក្យកាត់

## ស្ថាប័នរដ្ឋាភិបាល

| | | |
|---|---|---|
| CARD | Council for Agricultural and Rural Development | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

## អង្គការសហប្រជាជាតិ/អង្គការមិនមែនរដ្ឋាភិបាល/ស្ថាប័ននានា

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| HKI | Helen Keller International | ហេលិន ខេល័រ អន្តរជាតិ |
| ILO | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| SNV | Netherlands Development Organisation | អង្គការអភិវឌ្ឍន៍ហូឡង់ |
| UNICEF | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WFP | World Food Programme | កម្មវិធីស្បៀងអាហារពិភពលោក |

## ពាក្យកាត់ផ្សេងៗ

| | | |
|---|---|---|
| BCC | Behaviroual Change Communications | ផ្លាស់ប្តូរឥរិយាបថ តាមរយៈការប្រាស្រ័យទាក់ទង |
| HGSF | Home Grown School Feeding | កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ |
| IFA | Iron and Folic Acid | ជីវជាតិដែក និងអាស៊ីតហ្វូលីក |
| SDG | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |

# សេចក្តីផ្តើម

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨ ត្រូវបានរៀបចំឡើងសម្រាប់បំពេញបន្ថែមយុទ្ធសាស្ត្រ និងផែនការនានាដែលមានស្រាប់ ហើយបានបញ្ចូលធាតុផ្សំនានាពីយុទ្ធសាស្ត្រទាំនោះ បង្កើតចេញជាក្របខ័ណ្ឌមួយ សម្រាប់បង្កើតជាកម្លាំងផ្តួប ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យបានល្អបំផុត សម្រាប់ប្រជាពលរដ្ឋកម្ពុជា។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨ មានគោលដៅ "ត្រឹមឆ្នាំ ២០១៨ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់"។

ការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ធ្វើការពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន ក្រោមក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ គិតត្រឹមចុងឆ្នាំ ២០១៦ ក៏ដូចជាផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពគ្រប់ជ្រុងជ្រោយអំពីស្ថានភាពបច្ចុប្បន្ន និងសម្រេចកិច្ចខិតខំប្រឹងប្រែង ដែលត្រូវបន្តអនុវត្ត ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម ដែលនឹងកើតមានឡើងនាពេលអនាគត។ ការវាយតម្លៃយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិនេះ ត្រូវបានធ្វើឡើង ដោយប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់ ពិនិត្យឡើងវិញលើឯកសារ វិភាគ និងរៀបចំផែនការ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម៖

១. ពិនិត្យលើសមិទ្ធផល ដែលសម្រេចបានកន្លងមក រហូតដល់ឆ្នាំ ២០១៦ ក្រោមក្របខ័ណ្ឌនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

២. ពិនិត្យឡើងវិញ លើបញ្ហាប្រឈម និងឧបសគ្គ ដែលរារាំងដល់ការសម្រេចយុទ្ធសាស្ត្រនេះ និងវិធានការ ដើម្បីដោះស្រាយលើបញ្ហាទាំងនេះ។

៣. ពិចារណាលើសកម្មភាពដែលនៅសេសសល់ ក្រោមក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ គិតនៅត្រឹមចុងឆ្នាំ ២០១៦ និងធ្វើបច្ចុប្បន្នភាពផែនការនានា ដើម្បីឈានទៅបញ្ចប់ឱ្យបានត្រឹមឆ្នាំ ២០១៨។

៤. ធ្វើការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភបច្ចុប្បន្នឱ្យបានជាក់លាក់ ដោយប្រើប្រាស់ការវិភាគបែបអន្តរវិស័យ តាមរយៈការបញ្ចូលទស្សនវិស័យរបស់តួអង្គពាក់ព័ន្ធផ្សេងៗនៅកម្រិតអន្តរវិស័យ។

៥. រៀបចំផែនទីបង្ហាញផ្លូវឆ្ពោះទៅឆ្នាំ ២០៣០ និងដាក់ចេញនូវមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩ - ២០២៣។

៦. ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិនេះឱ្យបានទូលំទូលាយ។

៧. ធានាយ៉ាងណាឱ្យរាល់ទិន្នន័យ ឧបករណ៍ ដែលប្រើប្រាស់ និងឯកសារនានា ដែលប្រមូលសម្រាប់ការវាយតម្លៃយុទ្ធសាស្ត្រពាក់កណ្តាអាណត្តិនេះ ត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាព និងអាចឱ្យគេចូលមើលបាន តាមរយៈការបង្កើតនូវមូលដ្ឋានព័ត៌មានរួមមួយ។

ការវាយតម្លៃយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិនេះ ឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធនៃ យុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ និងឆ្លើយតបទៅនឹងគោលបំណង លំអិត បែងចែកទៅតាមអាទិភាពចំនួនបីដូចខាងក្រោម៖

១. ភាពមានស្បៀង និងការទទួលបានស្បៀង នៅកម្រិតគ្រួសារ (ជាពិសេសនៅតាមតំបន់ជនបទ)

២. ការប្រើប្រាស់ និងការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងមាតា (ផ្តោតលើរយៈពេល ១.០០០ ថ្ងៃដំបូង)

៣. ភាពងាយរងគ្រោះរបស់ក្រុមជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង និងភាពងាយប្រឈមរបស់ពួកគេ ទៅនឹងហានិភ័យនានា។

ចំណុចអាទិភាពទាំងនេះ (រូបភាពទី ១) ជារចនាសម្ព័ន្ធណែនាំសម្រាប់ការអនុវត្តន៍យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨ នេះ។ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពរបស់យុទ្ធសាស្រ្តនេះ ចាំបាច់ត្រូវមានការពិចារណាអំពីការរៀបចំស្ថាប័នសម្រាប់កែលម្អការស្វែងរកមតិគាំទ្រ ការសម្របសម្រួល ការពិនិត្យតាមដាន និងការវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងការកសាងសមត្ថភាព។ ការវាយតម្លៃលើដំណើរការអនុវត្តយុទ្ធសាស្រ្តនេះត្រូវធ្វើឡើងដោយពិចារណាលើ អភិបាលកិច្ចវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយចាត់ទុកការងារអភិបាលកិច្ចនេះ ថាជាការងារនៅកម្រិតអន្តរវិស័យ ព្រមទាំងពិចារណាលើក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌគតិយុត្ត ក៏ដូចជាការចូលរួមពីសហគមន៍ទូទៅផងដែរ។




រូបភាពទី ១៖ អាទិភាព ដែលឆ្លើយតបដោយផែនការយុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០១៤ - ២០១៨

ដំបូង ការវាយតម្លៃយុទ្ធសាស្ត្រពាក់កណ្ដាលអាណត្តិនេះ តម្រូវឱ្យមានការអង្កេតស្រាវជ្រាវពីវឌ្ឍនភាពដែលសម្រេចបានជុំវិញសកម្មភាពជាអាទិភាពដែលត្រូវបានដាក់ចេញក្នុង យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការប្រមូលរបាយការណ៍ពីក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដែលទទួលខុសត្រូវចម្បងតាមអាទិភាពនីមួយៗ។ ឯកសារនេះបង្ហាញដោយសង្ខេបពីវឌ្ឍនភាពដែលសម្រេចបានតាមអាទិភាពនីមួយៗនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨។ ឯកសារនេះជាឯកសារក្តោបរួមលើធាតុចូល ទទួលបានពីប្រភពទាំងអស់ដែលផ្តល់លទ្ធភាពឱ្យយើងអាចរៀបចំកិច្ចពិគ្រោះយោបល់ពិភាក្សាពីលទ្ធផលរកឃើញ និងបូកសរុបព័ត៌មាន ដែលបានទទួលពីឯកសារទាំងនេះ។ ខ្លឹមសារនៃឯកសារទាំងនេះ ត្រូវបានយកមករៀបរៀងក្នុងទម្រង់ជារបាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពដែលសម្រេចបាន ព្រមទាំងបញ្ហាប្រឈម និងអនុសាសន៍សំខាន់ៗ។

# របាយការណ៍សង្ខេបនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិត្រឹមឆ្នាំ២០១៦

## វឌ្ឍនភាពដែលសម្រេចបានជារួម

វិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភ បានទទួលការគាំទ្រពេញទំហឹងពីតួអង្គពាក់ព័ន្ធនានា។ ការគាំទ្រនេះមានរហូតទៅដល់កម្រិតខ្ពស់បំផុតនៅប្រទេសកម្ពុជា ឆ្លុះបញ្ចាំង តាមរយៈគោលនយោបាយនានា និងការចេញសារាចរណ៍នៅកម្រិតខ្ពស់ ពីរាជរដ្ឋាភិបាលកម្ពុជា និងការអនុវត្តសកម្មភាពរួមគ្នា ដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នៅទូទាំងប្រទេស។ ការគាំទ្រនេះធ្វើឡើងដោយសារមានយល់ឃើញថា មូលហេតុមួយចំនួនដែលនាំឱ្យមានកង្វះអាហារូបត្ថម្ភទទួលរងឥទ្ធិពលពីកត្តានានា នៅកម្រិតអន្តរវិស័យ ហើយបញ្ហាមួយចំនួនទាមទារឱ្យមានការប្រើប្រាស់អភិក្រមចម្រុះ (កសិកម្ម សុខភាព អភិវឌ្ឍន៍ជនបទ អប់រំ ។ល។) បញ្ចូលគ្នា ទើបអាចដោះស្រាយបាន។ ដើម្បីយល់ពីបញ្ហាអាហារូបត្ថម្ភ គេតោងយល់ពីកត្តាដ៏សែនស្មុគស្មាញ ដែលជាមូលហេតុជាមូលដ្ឋានផង និងមូលហេតុដែលនៅពីក្រោយផងនៃបញ្ហានេះ។

រាល់សកម្មភាពជាអាទិភាពដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨ សុទ្ធតែបានសម្រេចវឌ្ឍនភាពក្នុងការអនុវត្ត។ ជារួម រាល់សកម្មភាពជាអាទិភាពទាំងអស់ សុទ្ធតែកំពុងត្រូវបានអនុវត្ត ប៉ុន្តែពុំមានការគ្របដណ្តប់ដូចៗគ្នា ទូទាំងប្រទេសឡើយ។ សមត្ថភាពរាយការណ៍ពីលទ្ធផល ដែលសម្រេចបាន ក្រោមកម្មវិធីនានារបស់រាជរដ្ឋាភិបាលកម្ពុជា នៅមានកម្រិតនៅឡើយ លើកលែងតែរបាយការណ៍ស្តីពីផលិតកម្មកសិកម្ម ការអនុវត្តកម្មវិធីសុខាភិបាល និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការបែងចែកដីធ្លី។ គេពិបាកនឹងធ្វើការកំណត់ថា តើសកម្មភាពទាំងនេះបានរួមចំណែកលើកកម្ពស់លទ្ធផលសន្តិសុខស្បៀង និងអាហារូបត្ថម្ភយ៉ាងដូចម្តេចខ្លះនោះណាស់ ទាល់តែគេពិនិត្យលើព័ត៌មានលម្អិតបានពីគម្រោង ដែលត្រូវបានអនុវត្តរួមគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ ហើយរបាយការណ៍បានពីសកម្មភាពចម្រុះទាំងនេះទៀតសោត ក៏ពុំបានផ្តល់នូវតឹកតាង សម្រាប់ឱ្យយើងអាចពិនិត្យលើវឌ្ឍនភាពដែលសម្រេចបានឱ្យបានគ្រប់ជ្រុងជ្រោយនោះដែរ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (២០១៥) បានបង្ហាញពីវឌ្ឍនភាពសម្រេចបាននៅទូទាំងប្រទេស នៃសូចនាករសំខាន់ៗ ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ដូចជាបញ្ហាក្រិសក្រិន និងបញ្ហាស្គមស្គាំង ផ្ទុយពីនិន្នាការកាលពីពេលមុន នៅពេលដែលវឌ្ឍនភាពជុំវិញសកម្មភាពមួយចំនួននៅទ្រឹង។ ពុំមានទិន្នន័យថ្នាក់ជាតិ សម្រាប់ធ្វើបច្ចុប្បន្នភាពលទ្ធផលត្រឹមចុងឆ្នាំ ២០១៦ ឡើយ។ ការសិក្សាលម្អិតក្នុងវិស័យមួយចំនួន បានបង្ហាញថា កង្វះអាហារូបត្ថម្ភប្រែប្រួលខុសៗគ្នា ទៅតាមទីតាំងភូមិសាស្ត្រ និងក្រុមប្រជាសាស្ត្រ ដោយបញ្ហាគួរឱ្យព្រួយបារម្ភមួយចំនួននៅបន្តកើតមាន ជាពិសេស ការកើនឡើងនៃបញ្ហាលើសទម្ងន់ និងបញ្ហាធាត់ជ្រុល។

នៅកម្ពុជា ការទទួលបានទឹកស្អាត និងសេវាអនាម័យ ក៏ដូចជាការប្រកាន់ទម្លាប់អនាម័យផ្ទាល់ខ្លួន មានភាពល្អប្រសើរជាងមុន។ ទឹកស្អាត និងអនាម័យជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗដែលរួមចំណែកធ្វើឱ្យកុមារមានបញ្ហាអាហារូបត្ថម្ភស្រួចស្រាវនិងរ៉ាំរ៉ៃ។ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ បានសម្រេចនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់ការទទួលបានទឹកស្អាត និងការកែលម្អស្ថានភាពអនាម័យនៅតំបន់ជនបទ ដោយភូមិជាច្រើនត្រូវបានប្រកាសថា ជាភូមិដែលពុំមានការបន្ទោបង់ពាសវាលពាសកាល។ នៅតាមតំបន់មួយចំនួន សូចនាករសំខាន់ៗបង្ហាញថា មានការសម្រេចបានវឌ្ឍនភាពទៅតាមផែនការដែលបានគ្រោងទុក ដើម្បីឈានទៅសម្រេចចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយការគ្របដណ្តប់នៃសេវាអនាម័យសម្រេចបានលើសពីចំណុចដៅ ដាក់ចេញក្នុងឆ្នាំ ២០១៦ សម្រាប់ផែនការយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ នេះគឺជាការរួមចំណែកគួរឱ្យកត់សម្គាល់មួយ ចំពោះការលើកកម្ពស់លទ្ធផលសុខភាព និងអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមតំបន់ជនបទ។

ការទទួលបានទឹកស្អាតនៅតាមសាលាបឋមសិក្សា សម្រាប់គោលបំណងអនាម័យផង និងសម្រាប់ប្រើប្រាស់នៅក្នុងបង្គន់ផង មានការកើនឡើង បើទោះបីជាខេត្តប្រហែលជាពាក់កណ្តាលនៅមានការគ្របដណ្តប់ក្រោម ៦០ ភាគរយ យ៉ាងណាក្តី។ ដោយឡែកនៅកម្រិតអប់រំមធ្យមសិក្សាវិញ ការទទួលបានទឹកស្អាតប្រើប្រាស់ មានការកើនឡើងគ្រប់ខេត្តទាំងអស់ ដោយការគ្របដណ្តប់ត្រូវបានគេប៉ាន់ប្រមាណថាមានលើសពី ៦០ ភាគរយ លើកលែងតែខេត្ត ២ ចេញ (គឺពោធិ៍សាត់ និងប៉ៃលិន)។ ប៉ុន្តែ គុណភាពទឹកនៅតែបន្តជាការព្រួយបារម្ភ ដោយសារតែនៅពុំទាន់មានការធ្វើតេស្តគុណភាពទឹក នៅឡើយ។

រយៈពេលប្រមាណឆ្នាំចុងក្រោយនេះ វិស័យកសិកម្មបន្តមានកំណើន ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ដោយសារការប្រែប្រួលអាកាសធាតុ ផលិតភាពនៅមានកម្រិតទាប និងការថយចុះតម្លៃទំនិញលើទីផ្សារសកលលោក ព្រមទាំងការបោះជំហាននៃសេដ្ឋកិច្ចរបស់កម្ពុជា ពីសេដ្ឋកិច្ចផ្អែកលើកសិកម្ម ទៅជាសេដ្ឋកិច្ចផ្អែកលើសេវាកម្ម និងឧស្សាហកម្មវិញ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព សម្រាប់ការបន្តរក្សាកំណើនប្រកបដោយចីរភាព ដូចលើកឡើង ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ - ២០១៨។ រាជរដ្ឋាភិបាលកម្ពុជា នឹងយកចិត្តទុកដាក់ ដោះស្រាយបញ្ហាផលិតភាពទាបក្នុងវិស័យកសិកម្ម តាមរយៈ (១) ការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងប្រព័ន្ធធារាសាស្ត្រ (២) ការពង្រឹងការប្រើប្រាស់ពូជដំណាំល្អៗ និងបង្កើនការផ្តល់សេវាបច្ចេកទេស រួមទាំងសេវាផ្សព្វផ្សាយផងដែរ (៣) ការជំរុញឱ្យមានការដាំដុះដំណាំកសិឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ និង (៤) ការផ្តល់ឥណទានក្នុងតម្លៃសមរម្យ។ រដ្ឋាភិបាលក៏នឹងយកចិត្តទុកដាក់ជាពិសេស ចំពោះវិស័យវារីវប្បកម្ម និងការចិញ្ចឹមសត្វ ហើយក្នុងពេលជាមួយគ្នា គិតគូរពី វនិរន្តរភាពបរិស្ថាន។ ទន្ទឹមគ្នានឹងមានការផ្តោតការយកចិត្តទុកដាក់លើផលិតកម្ម ការអភិវឌ្ឍពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់វិស័យកសិកម្ម នឹងមានការខិតខំមិនឱ្យមានការភ្លេចគិតគូរពីការព្រួយបារម្ភពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងសន្តិសុខស្បៀង។

ក្រសួងអភិវឌ្ឍន៍ជនបទ ក៏សម្រេចបាននូវវឌ្ឍនភាពសំខាន់ៗជាច្រើនផងដែរ ខាងវិស័យដឹកជញ្ជូនជនបទ ដោយការស្តារផ្លូវជនបទសម្រេចបានក្នុងភាគរយមួយខ្ពស់ ស្របតាមផែនការប្រចាំឆ្នាំ។ វឌ្ឍនភាពសម្រេចបានខាងបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផ្សេងទៀត ឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសនេះ និងបានបង្កើនឱកាសប្រកបមុខរបរចិញ្ចឹមជីវិតសម្រាប់ប្រជាពលរដ្ឋ នៅតាមជនបទ។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបន្តមានកំណើនខ្ពស់នៅក្នុងឆ្នាំ ២០១៤ - ២០១៦ ហើយទន្ទឹមគ្នាឱកាសការងារទទួលបានប្រាក់ឈ្នួល ក៏មានការកើនឡើងយ៉ាងឆាប់រហ័សផងដែរ។ ប៉ុន្តែសម្រាប់តំបន់មួយចំនួនវិញ ជាពិសេសសហគមន៍ជនបទតែម្តង ការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ នៅទីក្រុង

ខេត្តដទៃទៀត ឬប្រទេសជិតខាង មានសន្ទុះកើនឡើងកាន់តែខ្លាំងឡើង។ ចំនួនពលករចំណាកស្រុកកើនឡើងខ្លាំង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយផ្តល់ចំណូលយ៉ាងច្រើនដល់គ្រួសារ។ ទោះជាយ៉ាងណាក៏ដោយចំណាកស្រុក នាំមកនូវបញ្ហាសង្គមជាច្រើន និងជះឥទ្ធិពលលើស្ថានភាពសន្តិសុខស្បៀង និងសុខុមាលភាពរបស់សមាជិកគ្រួសារដែលត្រូវបានទុកចោលនៅផ្ទះ (ជាពិសេសកុមារអាយុក្រោម ៥ ឆ្នាំ) និងរបស់ពលករចំណាកស្រុកខ្លួនឯង។ កម្រិតប្រាក់ឈ្នួលនៅតាមតំបន់ជនបទមានការកើនឡើង ស្របពេលដែលចំនួនពលករនៅតាមតំបន់ជនបទមានការថយចុះ។ បញ្ហាទាំងនេះកាន់តែស្មុគស្មាញខ្លាំងឡើងៗ បើទោះបីជាសេដ្ឋកិច្ចរបស់កម្ពុជា ជាទូទៅ មានភាពល្អប្រសើរជាងមុនយ៉ាងណាក៏ដោយ។ បញ្ហាដែលរៀបរាប់នេះកាន់តែរំលេចឱ្យឃើញពីសារៈសំខាន់នៃការប្តេជ្ញាចិត្ត ក្រោមក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ដែលចែងថា ពុំគួរទុកនរណាម្នាក់ចោលក្នុងដំណើរផ្លូវឆ្ពោះទៅសម្រេចការអភិវឌ្ឍប្រកបដោយចីរភាពឡើយ។

ការបណ្តុះបណ្តាលវិជ្ជាជីវៈ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ឱ្យពលករអាចផ្លាស់ប្តូរពីការងារមួយទៅការងារមួយទៀត និងសម្រាប់ឱ្យពួកគេអាចទទួលបានចំណូលខ្ពស់ពីការងាររបស់ខ្លួន។ ការពង្រីកកម្មវិធីសិក្សា ដោយបញ្ចូលការអប់រំវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញ នៅតាមសាលាមធ្យមសិក្សា គឺជាការងារដែលចាំបាច់ ដែលតម្រូវឱ្យមានធនធាន និងគ្រូដែលមានសមត្ថភាព។ តម្រូវការធនធានក៏ជាបញ្ហាចោទសម្រាប់ការពង្រឹងស្ថាប័ន ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការទទួលបានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនជីវិត ព្រមទាំងការលើកកម្ពស់ និងការអប់រំសុខភាព និងអាហារូបត្ថម្ភផងដែរនោះ។

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីខែ សីហា ឆ្នាំ ២០១៤។លទ្ធផលមួយក្នុងចំណោម លទ្ធផលនានាដែលសម្រេចបានដំបូងៗ ក្រោមយុទ្ធសាស្ត្រនេះ គឺការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤ - ២០២០ និងការពិគ្រោះយោបល់លើផែនការវិនិយោគរវាងក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី ៥៣ នៃចលនាបង្កើនអាហារូបត្ថម្ភ កាលពី ខែ កក្កដា ឆ្នាំ ២០១៤។ដោយសារមានការសហការគ្នាយ៉ាងជិតស្និទរវាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ក្រសួងសុខាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានរៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងរាយការណ៍មួយ សម្រាប់តាមដានវឌ្ឍនភាព ធៀបនឹងគោលបំណងដែលត្រូវបានដាក់ចេញក្នុងចលនាបង្កើនអាហារូបត្ថម្ភ ក៏ដូចជាផែនទីបង្ហាញផ្លូវ ដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភ។

ផែនការសកម្មភាពជាតិកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា ២០១៦-២០២៥ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែ ឧសភា ឆ្នាំ ២០១៦ ដែលជាផែនទីបង្ហាញផ្លូវគ្រប់ជ្រុងជ្រោយមួយ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ២ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ និងការធ្វើកសិកម្មប្រកបដោយចីរភាព។

រាជរដ្ឋាភិបាលកម្ពុជាក៏សម្រេចបានវឌ្ឍនភាពសំខាន់ៗ ក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា ធានាបាននូវសង្គតិភាព និងមាន ប្រសិទ្ធភាព គ្របដណ្តប់លើវិស័យសាធារណៈផង និងវិស័យឯកជនផង ដោយមានការបែងចែកតួនាទីច្បាស់លាស់ ជុំវិញការតាក់តែងគោលនយោបាយ ការធ្វើនិយ័តកម្ម និងការអនុវត្ត។ ជាមួយយនឹងធាតុចូលពីក្រសួងពាក់ព័ន្ធ និងពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចខិតខំប្រឹងប្រែងពហុវិស័យមួយ ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម ២០១៦-២០២៥ ដែលមានសសរស្តម្ភសំខាន់ៗចំនួនពីរ គឺ៖ ជំនួយសង្គម និងធានារ៉ាប់រងសង្គម។

## អាទិភាពទី ១៖ ភាពមានស្បៀង និងការទទួលបានស្បៀងប្រកបដោយនិរន្តរភាព នៅកម្រិតគ្រួសារ

អាទិភាពនេះ មានគោលដៅបង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វ ដែលកាន់តែមានភាពចម្រុះ និងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។

ខាងក្រោមអាទិភាពទី ១ ភាពមានស្បៀង និងការទទួលបានស្បៀងប្រកបដោយនិរន្តរភាព នៅកម្រិតគ្រួសារ បានទទួលការឆ្លើយតបតាមរយៈការធ្វើប្រពលវប្បកម្ម ពិពិធកម្ម និងសមាហរណកម្មទីផ្សារចំពោះប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច ការបែងចែកដីធ្លី និងការផ្តល់ប្លង់ដីជូនដល់ជនក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ការលើកកម្ពស់លទ្ធភាព ក្នុងការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជលផល និងព្រៃឈើដែលជាទ្រព្យសម្បត្តិរួម សម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។ខណៈពេលដែលការមានស្បៀងមិនមែនជាបញ្ហាធំនៅកម្ពុជា(បើគិតពីស្បៀងដែលផលិតបាននៅក្នុងស្រុក និងស្បៀងនាំចូល) បញ្ហាអសន្តិសុខស្បៀងតាមរដូវ ភាពចម្រុះនៃអាហារ និងការទទួលបានអាហារ ដែលសម្បូរដោយសារធាតុចិញ្ចឹម នៅតែជាបញ្ហាសំខាន់ៗ ដែលនាំឱ្យមានបញ្ហាអាហារូបត្ថម្ភ។

### ១.១ ធ្វើប្រពលវប្បកម្ម បង្កើនពិពិធកម្មប្រព័ន្ធកសិកម្ម និងលើកកម្ពស់សមាហរណកម្មទីផ្សាររបស់កសិករខ្នាតតូច

នៅក្នុងអំឡុងឆ្នាំ ២០១៤-២០១៦ ផលិតកម្មកសិកម្មបានសម្រេចនូវលទ្ធផលជារួមគួរជាទីពេញចិត្ត ទោះបីជាគ្រោះមហន្តរាយធម្មជាតិបានកើតឡើង ព្រមទាំងមានការធ្លាក់ភ្លៀងយឺត ការឆាប់កើតឡើងនូវរដូវប្រាំង និងការកើតគ្រោះទឹកជំនន់នៅចុងរដូវវស្សាក៏ដោយ។ ស្ថានភាពទាំងនេះបានទទួលការឆ្លើយតបតាមរយៈការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការណែនាំ និងការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ កសិករទូទាំងប្រទេស និងការរួមចំណែកពីដៃគូអភិវឌ្ឍន៍។

ប្រពលវប្បកម្មកសិកម្មបានក្លាយជាអាទិភាពមួយសម្រាប់កម្ពុជា។ ការពង្រីក និងការកែលម្អសេវាគាំទ្រ ដូចជា ការស្រាវជ្រាវ ការផ្សព្វផ្សាយបច្ចេកវិទ្យាថ្មី ការចែកគ្រាប់ពូជ ជី និងធនធានកសិកម្ម និងការផ្តល់កម្ចីនៅជនបទគឺជាអាទិភាពដែលរដ្ឋាភិបាលបានដាក់ចេញដើម្បីបង្កើនផលិតភាពកសិកម្ម និងបំពេញទៅតាមតម្រូវការទីផ្សារ ទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារអន្តរជាតិ។

បញ្ហាប្រឈមពាក់ព័ន្ធនឹងការដាំដុះកើតឡើងមួយផ្នែកដោយសារ ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះពឹងអាស្រ័យលើទឹកភ្លៀង ព្រោះតែបម្រែបម្រួលនៃកម្ពស់ទឹកភ្លៀង និងការប្រែប្រួលអាកាសធាតុ។ សហគមន៍កសិកម្ម ដែលរដ្ឋាភិបាលចាត់ទុកថាជាតួអង្គសំខាន់ៗចំពោះសេដ្ឋកិច្ចជនបទ មានសមត្ថភាពនៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត នាពេលអនាគត។ ការចូលរួមរបស់ការវិនិយោគឯកជន ក្នុងវិស័យកសិកម្ម ក៏នៅមានកម្រិតទាប បើធៀបជាមួយនឹងវិស័យដទៃទៀត ជាពិសេសការវិនិយោគក្នុងទ្រង់ទ្រាយមធ្យម និងធំ លើការកែច្នៃកសិផល។ ការចិញ្ចឹមសត្វសម្រេចបានវឌ្ឍនភាពពុំបានដូចៗគ្នាឡើយ ដោយសារតែសត្វពាហនៈដែលប្រើប្រាស់ជាកម្លាំងអូសទាញ ត្រូវបានជំនួសមកវិញដោយការប្រើគ្រឿងចក្រ និងដោយសារមានការថយចុះនូវផ្ទៃដីវាលស្មៅ ការប្រែប្រួលអាកាសធាតុ និងប្រភពទឹក។ ផលិតភាពរបស់សហគ្រាសចិញ្ចឹមសត្វបន្តមានការកើនឡើង ជាការឆ្លើយតបទៅនឹងកំណើនតម្រូវការផលិតផលដើមកំណើតពីសត្វ។

## ១.២ បង្កើនការទទួលបានដីធ្លីប្រកបដោយនិរន្តរភាព និងសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង

ការទទួលបានដី ជាបញ្ហាប្រឈមដែលរីកធំទៅ។ ដោយទំហំដីគិតជាមធ្យម ដែលជាកម្មសិទ្ធិរបស់គ្រួសារកសិករខ្នាតតូច គឺស្ទើរតែមិនគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមជីវិត ធ្វើឱ្យពួកគេពុំអាចពង្រីករបរចិញ្ចឹមជីវិត និងនាំឱ្យរបរចិញ្ចឹមជីវិតរបស់ពួកគេងាយប្រឈមទៅនឹងហានិភ័យ បង្កឡើងដោយអាកាសធាតុ។ បញ្ហាគ្មានដី ក៏ជាបញ្ហាកាន់តែធំជាងមុនផងដែរ។ ការធ្វើចំណាកស្រុកមានទំនាក់ទំនងជាមួយនឹងការប្រែប្រួលនៃស្ថានភាពសង្គមសេដ្ឋកិច្ច និងដើរតួជាដំណោះស្រាយចំពោះបញ្ហាភាពក្រីក្រសម្រាប់ប្រជាពលរដ្ឋ ហើយទន្ទឹមគ្នាក៏ជាបញ្ហាចោទមួយផងដែរ ដែលធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៅជនបទ ដែលងាយរងគ្រោះ។ សម្បទានដីសង្គមកិច្ច គម្រោងផ្លាស់ប្ដូរកន្លែងតាំងទីលំនៅ ការស្តារដីផលិតកម្មតាមរយៈការដោះមីន និងការផ្ដល់កម្មសិទ្ធិពេញលេញ សុទ្ធតែជាមធ្យោបាយដើម្បីបង្កើនការទទួលបានដី ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះ ទំនងជាជួបនឹងការលំបាក ដោយសារការផ្លាស់ប្ដូរចំនួនប្រជាជនក្នុងទ្រង់ទ្រាយធំ ហើយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋដើម្បីរកការងារធ្វើ និងការផ្ញើប្រាក់ត្រឡប់មកផ្ទះវិញ បានក្លាយជាប្រភពដ៏សំខាន់សម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ការទទួលបានដីគឺជាកត្តាដ៏សំខាន់ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានអាហារប្រកបដោយជីជាតិគ្រប់គ្រាន់ ប៉ុន្តែមានកត្តា និងបញ្ហាប្រឈមជាច្រើនផ្សេងទៀតដែលគេចាំបាច់ត្រូវយកមកធ្វើការពិចារណា។

## ១.៣ ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានទ្រព្យសម្បត្តិរួមចំពោះវិស័យជលផល និងព្រៃឈើ

ការគ្រប់គ្រងធនធានធម្មជាតិ ដូចជា ធនធានព្រៃឈើ និងធនធានជលផល និងកំណែទ្រង់វិស័យនេះ គឺជាប្រធានបទដែលគេយកមកជជែកពិភាក្សាយ៉ាងផុលផុស។ ដើម្បីឱ្យមានការផ្លាស់ប្តូរ ទាមទារឱ្យមានការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងបទល្មើសព្រៃឈើ ការបរបាញ់សត្វព្រៃ និងការនេសាទខុសច្បាប់ ចាំបាច់ត្រូវមានការសម្របសម្រួលឱ្យបានរឹងមាំរវាងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងធនធានដែលជាទ្រព្យសម្បត្តិរួម ប្រកបដោយប្រសិទ្ធភាពគឺជាបញ្ហាប្រឈមដ៏ធំមួយដែលត្រូវដោះស្រាយក្រោមសម្ពាធដែលកើតឡើងដោយសារកំណើនប្រជាជន ការកើនឡើងនូវតម្រូវការ និងការចូលរួមពាក់ព័ន្ធរបស់ស្ថាប័នជាច្រើន។

ចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់លើការលើកកម្ពស់វារីវប្បកម្ម ដើម្បីបំពេញទៅតាមតម្រូវការរំពឹងទុក និងកាត់បន្ថយសម្ពាធមកលើត្រីធម្មជាតិ និងការចិញ្ចឹមត្រីតាមវាលស្រែ។

## ១.៤ លើកកម្ពស់ការងារ និងបង្កើតប្រាក់ចំណូល សម្រាប់គ្រួសារអសន្តិសុខស្បៀង

សេដ្ឋកិច្ចជាតិ បន្តកើនឡើងក្នុងអត្រាមួយខ្ពស់ក្នុងឆ្នាំ ២០១៤-២០១៦ ហើយអមជាមួយនឹងកំណើននេះ ឱកាសការងារមានប្រាក់ឈ្នួល ក៏កើនឡើងផងដែរ។ ប៉ុន្តែ នៅតាមតំបន់មួយចំនួន ជាពិសេសសហគមន៍ជនបទ ការធ្វើចំណាកស្រុករកការងារធ្វើ នៅតំបន់ប្រជុំជន ខេត្តដទៃទៀត ឬប្រទេសជិតខាង ក៏មានសន្ទុះកើនឡើងខ្លាំងផងដែរ។ ចំនួនពលករចំណាកស្រុកសរុប មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយពួកគេបានផ្ដល់នូវចំណូលកាន់តែច្រើនឡើង សម្រាប់ក្រុមគ្រួសារ បើទោះជាការធ្វើចំណាកស្រុកនេះ នាំឱ្យមានកើតឡើងនូវបញ្ហាសង្គមមួយចំនួន និងបង្កផលប៉ះពាល់ដល់សន្តិសុខស្បៀង និងសុខុមាលភាពរបស់សមាជិកគ្រួសារដែលទុកចោលនៅផ្ទះ និងពលករចំណាកស្រុកខ្លួនឯងក៏ដោយ។ កម្រិតប្រាក់ឈ្នួលនៅតំបន់ជនបទមានការកើនឡើង ខណៈពេលដែលចំនួនពលករនៅតំបន់ជនបទមានការថយចុះ។ បញ្ហាទាំងនេះរឹតតែស្មុគស្មាញខ្លាំងឡើងៗ បើទោះបីជាសេដ្ឋកិច្ចទាំងមូល

មានកំណើនខ្ពស់យ៉ាងណាក៏ដោយ។ នេះរំលេចឱ្យឃើញពីសារៈសំខាន់ពីការប្តេជ្ញាចិត្ត ក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលកំណត់ថា មិនគួរទុកនរណាម្នាក់ចោលឡើយ ក្នុងដំណើរផ្លូវឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនេះ។

## អាទិភាពទី ២៖ ការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ម្ហូបអាហារ សម្រាប់កុមារ និងមាតា ដោយផ្តោតការយកចិត្តទុកដាក់លើរយៈពេល ១.០០០ ថ្ងៃដំបូងនៃជីវិត

### ២.១ សុខភាព និងអាហារូបត្ថម្ភ

វិស័យសុខាភិបាល បានសម្រេចសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន ជាពិសេសចំណុចដៅភាគច្រើនពាក់ព័ន្ធនឹងសុខភាព ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ សមិទ្ធផលគួរឱ្យកត់សម្គាល់ រួមមានវឌ្ឍនភាពក្នុងការកាត់បន្ថយមរណភាពមាតា និងកុមារ ការកាត់បន្ថយការសាយភាយជំងឺរបេង និងការពង្រីកមូលនិធិសមធម៌សុខាភិបាលទូទាំងប្រទេស សម្រាប់ប្រជាពលរដ្ឋក្រីក្រប្រមាណជា ២០០.០០០០ គ្រួសារ។ ក៏មានការសម្រេចចំណុចដៅពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ (កាត់បន្ថយមរណភាពកុមារ) ផងដែរ។ ដោយឡែក ចំណុចដៅពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទី ៥ (លើកកម្ពស់សុខភាពមាតា) បានសម្រេចភាគច្រើន។

ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល បានសហការគ្នាបង្កើនប្រសិទ្ធភាព ការវិភាជន៍ថវិកា សម្រាប់វិស័យសុខាភិបាល។ កន្លងមក មានការបង្កើនថវិកាសម្រាប់វិស័យសុខាភិបាល។ បច្ចុប្បន្ននេះ រដ្ឋាភិបាលបានរួមបដិភាគ ៥០% ក្នុងមូលនិធិសមធម៌សុខាភិបាល ដែលជាធនធានដាក់ក្នុងកញ្ចប់តែមួយ។ រដ្ឋាភិបាលក៏មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការរ៉ាប់រងលើមូលនិធិសមធម៌សុខាភិបាលទាំងស្រុង ក្នុងរយៈពេល ៥ ឆ្នាំទៀត។ ការពង្រឹងការប្រមូលទិន្នន័យសុខាភិបាលជាប្រចាំ ពីវិស័យសុខាភិបាល និងពីវិស័យផ្សេងទៀតផង បានផ្តល់នូវព័ត៌មាន និងតឹកតាងសម្រាប់ប្រើប្រាស់ក្នុងការតាក់តែងគោលនយោបាយ ការរៀបចំផែនការ និងការពិនិត្យតាមដាន និងវាយតម្លៃ។

កាលពីខែ មករា ឆ្នាំ ២០១៦ ក្រសួងសុខាភិបាល បានរៀបចំថវិកាជាតិសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល (HSP3, 2016-2020) ហើយនេះជាលើកទីមួយ ដែលអាហារូបត្ថម្ភ ត្រូវបានបញ្ចូលទៅក្នុងថវិកាជាតិ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក និងយូនីសេហ្វ។ អភិក្រមកម្មវិធីដែលប្រើប្រាស់នៅក្នុងវិស័យសុខាភិបាល កំពុងបង្ហាញឱ្យឃើញពីភាគលាភសម្រាប់ការរៀបចំរបាយការណ៍ និងរៀបចំផែនការ។ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខទៀត គេត្រូវការថវិកាប្រមាណជា ២៤,៦ លានដុល្លារ សម្រាប់ការងារអាហារូបត្ថម្ភ ដែលនៅក្នុងនោះ ៥៤,៥% សម្រាប់ផ្គត់ផ្គង់ឱសថព្យាបាលបញ្ហាអាហារូបត្ថម្ភ៖ ៦ លានដុល្លារ សម្រាប់ព្យាបាលបញ្ហាអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរក្នុងរយៈពេល ៥ ឆ្នាំទៀត ៣,៧ លានដុល្លារ សម្រាប់ផ្តល់ជីវជាតិដែក និងអាស៊ីតហ្វូលីក (IFA) ប្រចាំថ្ងៃ ០,៥ លានដុល្លារ សម្រាប់ផ្តល់វីតាមីនអាបន្ថែម និង ៣ លានដុល្លារ សម្រាប់ការបន្ថែមម្សៅមីក្រូសារជាតិ។

លើសពីនេះ ក៏ចាំបាច់ត្រូវតែមានការបង្កើនថវិកា ដើម្បីឆ្លើយតបចំពោះបន្ទុកដែលបន្តកើតឡើងដោយសារបញ្ហាអាហារូបត្ថម្ភ ហើយថវិកាដែលវិភាជន៍ឱ្យក្រសួងសុខាភិបាល សម្រាប់ការងារអាហារូបត្ថម្ភមិនអាចរ៉ាប់រងចំណាយទាំងនេះបានទាំងស្រុងឡើយ។ ឯកសារបោះពុម្ពផ្សាយ ដែលធ្វើឡើងដោយក្រសួងសុខាភិបាល ក្រោមជំនួយពីអង្គការសុខភាពពិភពលោក និង CHAI បានធ្វើការប៉ាន់ប្រមាណពីចំណាយលើការថែទាំសុខភាពនៅកម្ពុជាពីឆ្នាំ ២០១២ ដល់ ២០១៤ (បោះពុម្ពផ្សាយកាលពីខែធ្នូ ឆ្នាំ ២០១៥)។ ឯកសារនេះបានបង្ហាញថា រដ្ឋាភិបាលចំណាយប្រាក់ចំនួន ២០០ លានដុល្លារ លើវិស័យសុខាភិបាល

ដែលក្នុងនោះមានតែ ០,៧៥ លានដុល្លារ តែប៉ុណ្ណោះ ដែលចំណាយសម្រាប់ការងារអាហារូបត្ថម្ភ។ ថវិកាភាគច្រើនក្នុងទឹកប្រាក់ ០,៧៥ លានដុល្លារនេះ ត្រូវបានប្រើប្រាស់ក្នុងការទិញគ្រាប់ថ្នាំជាតិដែក និងវីតាមីនអា។ បើគិតតាមតម្រូវការ (ការប៉ាន់ប្រមាណចំណាយនៃ HSP3) និងថវិកាវិភាជន៍ ក្នុងឆ្នាំ ២០១៤ គួរមានការវិនិយោគទឹកប្រាក់ ៣,៥ លានដុល្លារទៀត ចេញពីថវិការដ្ឋ និងពីថវិកាពីដៃគូអភិវឌ្ឍន៍។ ជាមួយនឹងធនធានតិចតួចបែបនេះ គេពិបាកនឹងពង្រីកការអនុវត្តគ្រប់សកម្មភាពទាំងអស់ ក្នុងផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភ។ សកម្មភាព ដូចជា ការពិនិត្យកុមារ ការបញ្ជូន និងការព្យាបាលករណីបញ្ហាអាហារូបត្ថម្ភស្រួចស្រាវត្រូវបានអនុវត្តតាមតំបន់ជនបទ ប៉ុន្តែ ចាំបាច់ត្រូវតែពង្រីកបន្ថែមទៀត។

សារៈសំខាន់នៃការបំបៅកូនតែទឹកដោះម្តាយតែមួយគត់សម្រាប់ទារករហូតដល់អាយុ៦ខែហាក់បីដូចជាត្រូវបានយល់ដឹងកាន់តែច្បាស់ ដោយស្ត្រីជាម្តាយនៅតាមតំបន់ភាគច្រើននៅកម្ពុជា។ បើតាមការអង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា ក្នុងឆ្នាំ ២០១៤ កុមារក្រោម ៦ ខែ ៦៥% បានទទួលការបំបៅដោយទឹកដោះម្តាយតែមួយគត់ ដែលភាគរយនេះថយចុះយ៉ាងច្រើន ពី ៧៤% កាលពីឆ្នាំ ២០១០។ កុមារនៅតាមតំបន់ជនបទ កុមារក្នុងគ្រួសារក្រីក្រ និងកុមារដែលម្តាយមានកម្រិតវប្បធម៌ទាប ទទួលបានការបំបៅទឹកដោះម្តាយតែមួយមុខគត់បានច្រើន និង ក្នុងរយៈពេលមួយកាន់តែយូរ។ ការយល់ដឹងអំពីសារៈសំខាន់ពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ នៅតែបន្តជាបញ្ហាប្រឈម ដោយសារតែសម្ពាធការងាររបស់ស្ត្រីដែលកំពុងធ្វើការ ជាពិសេសនៅតាមតំបន់ប្រជុំជន។ ចាំបាច់ត្រូវតែមានការបន្តកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការថយចុះស្ថិតិនៃការបំបៅកូនដោយទឹកដោះម្តាយ ជាពិសេសក្នុងចំណោមប្រជាជនដែលរស់នៅតំបន់ប្រជុំជន។

ក្នុងចំណោមកុមារអាយុ៦ទៅ២៣ខែ នៅកម្ពុជាចំនួនបីនាក់ មានម្នាក់តែប៉ុណ្ណោះ(៣០%)ដែលបានទទួលរបបអាហារក្នុងកម្រិតអប្បរមាដែលអាចទទួលយកបាន។ កុមារនៅតំបន់ជនបទទំនងជានឹងទទួលបានរបបអាហារក្នុងកម្រិតអប្បរមាដែលអាចទទួលយកបាន ទាបជាងកុមារនៅប្រជុំជនពីរដង ហើយកុមារមកពីគ្រួសារមានជីវភាពក្រីក្រជាងគេទំនងជាទទួលបានរបបអាហារកម្រិតអប្បរមា ទាបជាងកុមារមកពីគ្រួសារមានជីវភាពធូរធាជាងគេបួនដង។ ការវិភាគលើទិន្នន័យ ដែលមានស្រាប់នៅកម្ពុជា ក៏បង្ហាញផងដែរថា កុមារដែលទទួលទានអាហារពីដើមកំណើតពីសត្វមិនសូវជាមានកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃនោះឡើយ(ក្រេះក្រិន)។ អន្តរាគមន៍ ដែលប្រជាពលរដ្ឋនៅមូលដ្ឋានអាចទទួលយកបាន ដោយប្រើប្រាស់ភស្តុតាងជាគោលជាច្រើនត្រូវបានដាក់ឱ្យអនុវត្តដោយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្តោតលើការផ្តល់អាហារបន្ថែម។ មានអន្តរាគមន៍ខ្លះផ្តោតលើការបង្កើត និងការថែទាំសួនដំណាំតាមផ្ទះដែលដាំដំណាំសម្បូរដោយសារជាតិចិញ្ចឹម ខណៈពេលដែលអន្តរាគមន៍ខ្លះទៀតផ្តល់ដំណោះស្រាយ ដោយប្រើប្រាស់ធនធាន ដែលអាចរកបាននៅមូលដ្ឋាន ដូចជា ការផ្តល់ម្សៅដែលកិនពីត្រីតូចៗជាដើម។

## ២.២ ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាត និងការអនុវត្តអនាម័យ នៅក្នុងមូលដ្ឋាន

មានការសម្រេចបានចំណុចដៅពាក់ព័ន្ធនឹងទឹកស្អាត និងអានាម័យផ្ទាល់ខ្លួនក្នុងឆ្នាំ ២០១៦ ហើយចំណុចដៅពាក់ព័ន្ធនឹងអនាម័យបរិស្ថាន ត្រូវបានសម្រេចទៅតាមផែនការដែលបានគ្រោងទុក។ មានការសម្រេចបាននូវវឌ្ឍនភាពចម្រុះ ពាក់ព័ន្ធនឹងសកម្មភាពជាអាទិភាព ដែលទាមទារឱ្យមានតាមដានបន្តទៀតៈ សារអប់រំអំពីទឹកស្អាត និងអនាម័យ ត្រូវបានបញ្ចូលនៅក្នុងយុទ្ធនាការផ្សព្វផ្សាយអប់រំពីអាហារូបត្ថម្ភ និងឯកសារសម្ភារៈផ្លាស់ប្តូរឥរិយាបថ តាមរយៈការប្រាស្រ័យទាក់ទង (BCC) របស់ក្រសួងសុខាភិបាល ហើយសកម្មភាពអាហារូបត្ថម្ភ ពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ ទទួលបានការគាំទ្រពីតួអង្គកាន់តែច្រើន ប៉ុន្តែការអនុវត្តសកម្មភាពរួមគ្នា មិនទាន់ត្រូវបានធ្វើឡើងជាប្រចាំក្នុងកម្មវិធីជាតិនៅឡើយ ហើយបើទោះបីជា

ការងារជាច្រើនបានសម្រេចមានភាពជឿនលឿនទៅមុខយ៉ាងណាក៏ដោយ។ ក្រុមការងារផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ដែលទទួលបន្ទុករៀបចំយុទ្ធនាការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទងនៅថ្នាក់ជាតិ ជាក្រុមដែលមានសក្តានុពលក្នុងការអនុវត្តរបៀបវារៈនេះ។ ពាក់ព័ន្ធនឹងការងាររៀបចំផែនការ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការប៉ាន់ប្រមាណចំណាយសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (២០១៤-២០១៨) ដែលបានបញ្ចូលនូវអន្តរាគមន៍ជាច្រើនសម្រាប់ជួយលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភមាតានិងកុមារ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ការណែនាំជាក់លាក់អំពីការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យ និងអាហារូបត្ថម្ភ នៅមិនទាន់បានរៀបចំនៅឡើយ ហើយនៅមានចន្លោះប្រហោងជាច្រើន សម្រាប់លើកកម្ពស់ការឆ្លើយតបចំពោះស្ថានភាពអាហារូបត្ថម្ភ។ ភាពអាចដំណើរការទៅបាន និងនិរន្តរភាពនៃការងារទឹកស្អាត និងអនាម័យនៅតែជាបញ្ហាដោយហេតុថាពុំមានទិន្នន័យនៅថ្នាក់ជាតិ ប៉ុន្តែបើតាមទិន្នន័យដែលអាចរកបានពីគម្រោងនានា បញ្ហាទាំងនេះនៅតែជាបញ្ហាប្រឈម ដែលទាមទារឱ្យគេរៀបចំឯកសារណែនាំជាច្រើន ប៉ុន្តែក៏មានឯកសារមួយចំនួន ត្រូវបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូតាមវិស័យនានារួចទៅហើយ។ លើសពីនេះក៏ចាំបាច់ត្រូវមានការពង្រឹងទិន្នន័យ ដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ។

អនុក្រុមការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងអាហារូបត្ថម្ភ ត្រូវបានបង្កើតឡើង ក្រោមក្របខ័ណ្ឌនៃក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងអង្គការសង្គ្រោះកុមារជាសហប្រធាន។ អនុក្រុមការងារនេះមានតួនាទីដឹកនាំរៀបចំឯកសារសំខាន់ៗស្តីពីការធ្វើសមាហរណកម្ម និងការប្រមូលផ្តុំសកម្មភាពទឹកស្អាត និងអនាម័យ និងអាហារូបត្ថម្ភ បញ្ចូលគ្នានៅឆ្នាំ ២០១៦។

ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៦ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានដឹកនាំ ការរៀបចំទិវាជាតិអាហារូបត្ថម្ភប្រចាំឆ្នាំ លើកទី ៣ ដែលប្រធានបទផ្តោតលើផលប៉ះពាល់ដែលកើតឡើងពីទឹកស្អាត និងអនាម័យ និងទម្លាប់អាហារូបត្ថម្ភត្រឹមត្រូវ មកលើការចម្រើនវ័យប្រកបដោយសុខភាពល្អ និងការអភិវឌ្ឍកុមារនៅកម្ពុជា។ ព្រឹត្តិការណ៍នេះ មានអ្នកចូលរួមជាង ៧00 នាក់។ ទិវានេះត្រូវបានរៀបចំរួមគ្នាដោយរដ្ឋាភិបាលកម្ពុជា ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាសេនាធិការ រួមនឹងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល និងមានការសហការជាមួយ USAID UNICEF FAO WFP និង GIZ ក្រោមការគាំទ្រពីអង្គការសង្គ្រោះកុមារ អង្គការភ្លែនអន្តរជាតិ អង្គការសកម្មភាពប្រយុទ្ធនឹងភាពអត់ឃ្លាន អង្គការ Samaritan's Purse អង្គការ Medical Teams International និងអង្គការ Malteser International។

ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៦ នេះដែរ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងដៃគូអភិវឌ្ឍន៍ស្មួលមួយចំនួន បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី "ការកែលម្អអនាម័យ និងអាហារូបត្ថម្ភធ្វើឱ្យកុមារលូតលាស់បានល្អ៖ ចេញពីភស្តុតាង ទៅជាផលជះ។" អ្នកចូលរួមជិត ២00 នាក់ មានឱកាសពិនិត្យមើលទិន្នន័យចុងក្រោយគេ ដែលប្រមូលតាមរយៈការអង្កេតដើមគ្រា និងសិក្សាស្វែងយល់ពីអន្តរាគមន៍ថ្មីៗមួយចំនួន ដែលអនុវត្តដោយគម្រោង NOURISH របស់ USAID HKI និងអង្គការភ្លែនអន្តរជាតិ។

ការទទួលបានសេវាអនាម័យដែលត្រូវបានកែលម្អ និងការគ្រប់គ្រងទឹកស្អាត មានការកើនឡើង ហើយមានការសម្រេចបានលើសពីចំណុចដៅអនាម័យ សម្រាប់ឆ្នាំ ២០១៦។ គម្រោងសហគមន៍ដឹកនាំអនាម័យទាំងស្រុង និងការប្រើប្រាស់និងការថែទាំប្រភពទឹកនៅតាមភូមិត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងវិស័យនេះ។សម្រាប់ការគ្រប់គ្រងទឹកស្អាតវិញ មានការអនុវត្តសាកល្បងជាច្រើន ឧទាហរណ៍ ចាប់តាំងពីខែមីនាឆ្នាំ២០១៥ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទនិង គ.ជ.អ.ប ជាមួយនឹងការគាំទ្រពី

ADB និងជំនួយបច្ចេកទេសពី SNV បានសាកល្បងការធ្វើវិមជ្ឈការដំណើរការនិងតំហែទាំកន្លែងផ្គត់ផ្គង់ទឹកស្អាតក្នុងស្រុកចំនួនបួន នៅខេត្តកំពត។

## ២.៣ ពង្រឹកការបញ្ចូលមីក្រូសារជាតិ ទៅក្នុងចំណីអាហារ

ការបញ្ចូលមីក្រូសារជាតិនៅទៅក្នុងអាហារ និងការបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិល ត្រូវបានកំណត់យ៉ាងច្បាស់ក្នុងគោលនយោបាយមួយ ក្រោមក្របខ័ណ្ឌយុទ្ធជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨។ កម្ពុជាមានសមត្ថភាពបច្ចេកទេសផលិតផលិតផលទាំងនេះ បើទោះបីជាតម្រូវការនៅមានតិចតួច ហើយការពង្រឹងការគ្រប់គ្រងទីផ្សារនៅជាបញ្ហាចោទយ៉ាងណាក៏ដោយ។ បញ្ហាប្រឈមរួមមាន ការចូលរួមពីដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យឯកជននៅមានកម្រិត ជំនាញរបស់ស្ថាប័នអនុវត្តច្បាប់នៅតិចតួចដើម្បីធ្វើការងារនេះ ប្រព័ន្ធផ្សព្វផ្សាយមិនសូវជាចាប់អារម្មណ៍ ឬផ្តល់ការគាំទ្រ កង្វះការយល់ដឹងពីសាធារណជនទូទៅអំពីសារៈសំខាន់នៃមីក្រូសារជាតិ (អ៊ីយ៉ូដ ជាតិដែក វីតាមីនបេ១ ។ល។) និង កង្វះការវិភាជន៍ថវិកាសម្រាប់គាំទ្រដល់កម្មវិធី ដែលបង្ខំឱ្យកម្មវិធីនេះត្រូវពឹងអាស្រ័យលើសលុបលើការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ការកើនឡើងគួរឱ្យកត់សម្គាល់នូវប្រេវ៉ាឡង់អំបិលគ្មានជាតិអ៊ីយ៉ូដនៅកម្ពុជា ដែលត្រូវបានរកឃើញនៅក្នុងឆ្នាំ ២០១៥ ដែលនេះបង្ហាញពីភាពផុយស្រួយនៃកម្មវិធីជាតិបញ្ចូលសារជាតិអ៊ីយ៉ូដទៅក្នុងអំបិល នៅក្នុងករណីដែលមិនមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍។

## ២.៤ លើកកម្ពស់ការមានស្បៀង និងការប្រើប្រាស់ស្បៀងអាហារ ប្រកបដោយអាហារូបត្ថម្ភ និងមានសុវត្ថិភាពនៅកម្រិតគ្រួសារ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន និងកំពុងធ្វើការងារជាមួយនឹងដៃគូនានា ដើម្បីបញ្ជ្រាបអាហារូបត្ថម្ភទៅក្នុងការផ្សព្វផ្សាយកសិកម្ម តាមរយៈគោលនយោបាយស្តីពីការបញ្ជ្រាបយេនឌ័រ និងគោលនយោបាយស្តីពីការអភិវឌ្ឍ និងគាំពារកុមារ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កន្លងមកមានកិច្ចខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពគ្រូឧទ្ទេសពីថ្នាក់ជាតិ រហូតដល់ថ្នាក់សហគមន៍ តាមរយៈការសហការដោយជិតស្និទជាមួយនឹងមន្ត្រីកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។

## ២.៥ ការប្រើប្រាស់ឧបករណ៍គាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ

ឧបករណ៍គាំពារសង្គម ដែលផ្តោតការយកចិត្តទុកដាក់លើអាហារូបត្ថម្ភ ភាគច្រើនមាននៅក្នុងទម្រង់ជាការផ្តល់ជំនួយសង្គម។ ការអនុវត្តកម្មវិធីជាច្រើន ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដូចជា កម្មវិធីផ្តល់អាហារតាមសាលារៀន និងកម្មវិធីផ្តល់អាហារូបករណ៍ក្នុងទម្រង់ជាស្បៀងអាហារ ការផ្តល់ស្បៀងការងារ កម្មវិធីសាច់ប្រាក់ពលកម្ម និងកម្មវិធីផ្ទេរសាច់ប្រាក់ ជាដើម។

ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីស្បៀងអាហារពិភពលោក បានគាំទ្រដល់វិស័យអប់រំ តាមរយៈកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលកម្មវិធីនេះផ្តល់អាហារពេលព្រឹកសម្បូរដោយជីជាតិដល់កុមាររៀនតាមសាលាមត្តេយ្យ និងសាលាបឋមសិក្សា និងផ្តល់កម្មវិធីអាហារូបករណ៍ដល់កុមារមកពីគ្រួសារក្រីក្រ។ កម្មវិធីនេះគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យកុមារអាចទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស ដូចដែលមានចែងនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។ កម្មវិធីផ្តល់អាហារ (ដូចជា កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនធម្មតា និងកម្មវិធីស្បៀងអាហារតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍) ផ្តល់អាហារដល់សិស្សជាង ៣០០.០០០ នាក់ជាប្រចាំឆ្នាំ។ ចំណែកកម្មវិធីអាហារូបករណ៍ គ្របដណ្តប់លើសិស្សជាង ៤០០.០០០ នាក់ ក្នុងសាលាបឋមសិក្សាសរុប ២.៥៤៧ ដែលស្ថិតនៅតាមតំបន់អសន្តិសុខស្បៀង

ក្នុងខេត្តចំនួន ១១។ កម្មវិធីនេះ ក៏ផ្តោតការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ សកម្មភាពអប់រំ និងសកម្មភាពផ្សេងទៀត ដែលពាក់ព័ន្ធនឹងកម្មវិធីគិតគូរអំពីអាហារូបត្ថម្ភ។

សកម្មភាពផ្តល់អាហារូបករណ៍នៅក្នុងទម្រង់ជាអាហារ រួមមានជាការផ្តល់នូវរបបអាហារក្នុងរយៈពេលកំណត់មួយ ជាកម្មវិធីដែលមានការជ្រើសរើសអ្នកទទួលផលយ៉ាងហ្មត់ចត់ និងត្រូវបានអនុវត្តនៅតាមសាលាបឋមសិក្សាសម្រាប់សិស្សថ្នាក់ទី ៤ ដល់ទី ៦ (ដោយសារតែសិស្សនៅកម្រិតទាំងនេះ មានអត្រាបោះបង់ខ្ពស់ជាងគេ) មកពីគ្រួសារភាពក្រីក្រជាងគេ។ កម្មវិធីនេះ បំពេញតួនាទីជាមូលដ្ឋានសម្រាប់ពង្រីកសំណាញ់សុវត្ថិភាពសង្គម ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិគាំពារសង្គមដែលអនុវត្តដោយ ក្រសួងអប់រំ យុវជន និងកីឡា ដូចដែលស្តែងចេញតាមរយៈការបង្កើតកម្មវិធីអាហារូបករណ៍ជាតិសម្រាប់សិស្សបឋមសិក្សាកាលពីឆ្នាំ ២០១៤។

រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាចិត្តក្នុងការរិះរកជម្រើសផ្សេងៗ ដើម្បីផ្ទេរការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀននេះ ទៅឱ្យស្ថាប័នជាតិគ្រប់គ្រងត្រឹមឆ្នាំ ២០២១។ បើទោះបីជាប្រទេសកម្ពុជាកំពុងឈានក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតទាបយ៉ាងណាក៏ដោយ ការវិនិយោគលើវិស័យសង្គមនៅតែបន្តជួបនឹងឧបសគ្គគួរឱ្យកត់សម្គាល់ តួយ៉ាងការវិនិយោគសម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀននេះជាដើម។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងសុខាភិបាល បាននឹងកំពុងសហការគ្នាយ៉ាងជិតស្និតជាមួយគម្រោងNOURISHដែលទទួលបានការឧបត្ថម្ភថវិកាពីUSAIDដើម្បីពង្រីកទាំងការអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់មានលក្ខខណ្ឌ។ កម្មវិធីនេះ បានរួមចំណែកផ្ទាល់បង្កើនការប្រើប្រាស់សេវាសុខភាព និងអាហារូបត្ថម្ភសំខាន់ៗ។ គម្រោង NOURISH ធ្វើការងារជាក់លាក់ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ មេភូមិ និងអ្នកស្ម័គ្រចិត្តសុខភាព ដើម្បីកំណត់រកអ្នកទទួលផល និងធ្វើការតាមមណ្ឌលសុខភាព ដើម្បីបញ្ជាក់ថា អ្នកទទួលផលពិតជាបានបំពេញទៅតាមលក្ខខណ្ឌដែលបានកំណត់ទុកពិតប្រាកដមែន។ ក្រោមគម្រោង NOURISH នេះ គ្រួសារក្រីក្រដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង ក្នុងរយៈពេល ១.០០០ ថ្ងៃដំបូង មកពីខេត្តសៀមរាប ពោធិ៍សាត់ និងបាត់ដំបង ត្រូវបានចុះឈ្មោះឱ្យចូលរៀននៅក្នុងកម្មវិធីផ្ទេរសាច់ប្រាក់មានលក្ខខណ្ឌ។ ប្រជាពលរដ្ឋទាំងនេះមកពីភូមិចំនួន ៤៧៥ ក្នុងនោះជាងពាក់កណ្តាលបានទទួលការផ្ទេរសាច់ប្រាក់ យ៉ាងហោចណាស់ម្តង សម្រាប់ការបំពេញលក្ខខណ្ឌដែលបានកំណត់ដោយគម្រោងនេះ។ លើសពីនេះ ប័ណ្ណរួមចំណាយ ត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់ទិញធុងចម្រុះទឹកដែលផលិតក្នុងស្រុក សម្ភារបង្គន់អនាម័យ និងអាហារដែលសម្បូរដោយសារជាតិចិញ្ចឹម ដើម្បីលើកទឹកចិត្តឱ្យមានការបង្កើតទម្លាប់ប្រើប្រាស់ទឹកស្អាត សាងសង់ និងប្រើប្រាស់បង្គន់អនាម័យ និងលើកកម្ពស់របបអាហារចម្រុះសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន ក៏ដូចជាកុមារអាយុចន្លោះពី ៦ ខែ ដល់ ២ឆ្នាំ។

ក្នុងឆ្នាំ ២០១៥ អង្គការ HKI និងយូនីសេហ្វ បានធ្វើការវាយតម្លៃផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភរបស់ក្រសួងសុខាភិបាល។ សមាសភាគនីមួយៗនៅក្នុងផែនទីបង្ហាញផ្លូវនេះផ្តល់ជម្រើស សម្រាប់ជម្រុញឱ្យមានការចូលរួម និងផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ។ សកម្មភាពអនុវត្តតាមសហគមន៍ និងភូមិទាំងនេះ ជាសកម្មភាព ដែលអស់ចំណាយតិចតួច ដោយកម្មវិធីជាច្រើនចំណាយក្រោម ១ ភាគរយនៃថវិកាបដិភាគគិតជាមធ្យមរបស់ក្រុមប្រឹក្សាឃុំក្នុងឆ្នាំ ២០១៤ តែប៉ុណ្ណោះ។ ការគាំទ្រកម្រិតនយោបាយពីថ្នាក់ឃុំ អាចជួយកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុ ប៉ុន្តែកន្លងមក ពុំមានការផ្តល់ការគាំទ្របែបនេះឡើយ។

ការបណ្តុះបណ្តាលអំពីសុខភាព អនាម័យ និងអាហារូបត្ថម្ភ និងទឹកស្អាត និងអនាម័យ ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ នៅថ្នាក់ក្រោមជាតិ ដល់មន្រ្តីគោលដៅមួយចំនួន ក្នុងគោលបំណងបង្កើនការយល់ដឹងទូទៅរបស់ពួកគេ និងកែលម្អទម្លាប់ប្រចាំថ្ងៃរបស់ពួកគេ ជាពិសេសអ្នកដែលកំពុងធ្វើការងារនៅតាមសាលារៀនដែលមានអនុវត្តកម្មវិធីផ្តល់អាហារ។

ការធ្វើកសិកម្ម និងការដាំដំណាំក្នុងសាលា ត្រូវបានបញ្ចូលទៅហើយ ក្នុងកម្មវិធីបំណិនជីវិត នៅគ្រប់សាលាបឋមសិក្សា ក្នុងប្រទេសកម្ពុជា ហើយសួនបន្លែក្នុងសាលារៀនត្រូវបានបង្កើតឡើងក្នុងគ្រប់សាលារៀនទាំងអស់ ដែលមានអនុវត្តកម្មវិធីផ្តល់អាហារនៅតាមសាលារៀន។ បន្លែដាំដុះក្នុងកម្មវិធីនេះ ត្រូវបានប្រើប្រាស់ ដើម្បីផ្តល់បន្លែចម្រុះមុខ សម្រាប់បំពេញបន្ថែមលើអាហារពេលព្រឹក ដែលចម្អិនតាមសាលារៀននៅក្នុងគោលបំណងបំផុសឱ្យមានទម្លាប់ទទួលទានអាហារដែលនាំមកនូវសុខភាពល្អ និងលើកកម្ពស់អាហារូបត្ថម្ភ។ ចុងភៅទាំងអស់ បានទទួលការបណ្តុះបណ្តាលអំពីអនាម័យផ្ទាល់ខ្លួន និងអនាម័យបរិស្ថាន និងអាហារូបត្ថម្ភ ព្រមទាំងបានចូលរួមនៅក្នុងការបង្ហាញពីរបៀបចម្អិនម្ហូប ដើម្បីឱ្យពួកគេអនុវត្តឱ្យបានត្រឹមត្រូវ នៅក្នុងសកម្មភាពចម្អិនអាហារប្រចាំថ្ងៃរបស់ពួកគេ។ នៅក្នុងឆ្នាំ ២០១៦ អង្គការស្បៀងនិងអាហារនៃសហប្រជាជាតិបានសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំកម្មវិធីសិក្សាមួយសម្រាប់កម្មវិធីសួនបន្លែនៅតាមសាលារៀន និងបានបង្កើតគ្រូបង្គោលមួយក្រុមមកពីតាមស្ថាប័ននានារបស់រដ្ឋាភិបាល ដែលក្នុងនោះមានទាំងគ្រូបង្រៀនផងដែរ។

កម្មវិធីស្បៀងអាហារពិភពលោក កាំកុងត្រូល និងនាយកដ្ឋានសុខភាពសិក្សា បានចូលរួមបង្កើតភាពជាដៃគូជាឯកជនជាមួយក្រុមហ៊ុនអន្តរជាតិមួយឈ្មោះ Sodexo ដើម្បីរៀបចំការណែនាំ និងផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព បង្កើនការធានាគុណភាព និងសុវត្ថិភាពអាហារ ដែលផ្តល់តាមសាលារៀន។

## ២.៦ រៀបចំ និងសាកល្បងកម្មវិធីអាហារូបត្ថម្ភចម្រុះតាមសហគមន៍សម្រាប់ប្រទេសកម្ពុជា ដែលអនុវត្ត តាមរយៈអាជ្ញាធរមូលដ្ឋាន

ជាផ្នែកមួយនៃចលនាបង្កើនអាហារូបត្ថម្ភ សម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ នៅកម្ពុជាត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់រដ្ឋាភិបាល ក្នុងការសម្រេចទៅតាមការប្តេជ្ញាចិត្តរបស់ខ្លួន ហើយនៅក្នុងពេលជាមួយគ្នាក៏ធ្វើការងារដើម្បីឱ្យរដ្ឋាភិបាលមានគណនេយ្យភាពផងដែរ។ សម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភនៅកម្ពុជា មានសមាជិក ៣៥ អង្គការ ដែលកំពុងអនុវត្តសកម្មភាពនៅក្នុងខេត្តរាជធានីទាំង ២៥។ ក្នុងយុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ មានការដាក់ចេញនូវសកម្មភាពកម្មវិធីជាអាទិភាពមួយ សម្រាប់បង្កើត និងសាកល្បងកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ សម្រាប់កម្ពុជា ដែលសកម្មភាពជាអាទិភាពនេះត្រូវបានទទួលយកដោយសម្ព័ន្ធសង្គមស៊ីវិល តាមរយៈការធ្វើការងាររួមជាមួយនឹងកម្មវិធីរបស់រាជរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទជាមួយនឹងរដ្ឋាភិបាល ជាពិសេសនៅថ្នាក់ក្រោមជាតិ។សម្ព័ន្ធសង្គមស៊ីវិលក៏បានចូលរួមបំពេញតួនាទីប្រកបដោយការជឿជាក់ក្នុងក្រុមការងារបច្ចេកទេស និងស្ថាប័នផ្តល់ប្រឹក្សាផងដែរ។

សមាជិកនៃសម្ព័ន្ធសង្គមស៊ីវិលសម្រាប់ចលនាបង្កើនអាហារូបត្ថម្ភ ចំនួន ៧ នៅក្នុងចំណោមសមាជិកទាំង ១៣ បានផ្តល់របាយការណ៍ សម្រាប់ឆ្នាំ ២០១៦ អំពីអន្តរាគមន៍ផ្តោតលើអាហារូបត្ថម្ភ ឬអន្តរាគមន៍គិតគូរពីអាហារូបត្ថម្ភ។ របាយការណ៍ទាំងនេះ នឹងជួយបង្កើតនូវតឹកតាង សម្រាប់ពង្រីកសកម្មភាពមួយចំនួនបន្ថែមទៀត។ សកម្មភាពជាច្រើន នៅកំពុងស្ថិតនៅក្នុងដំណាក់កាលអនុវត្តនៅឡើយ ដូច្នេះគេពុំទាន់អាចប្រមូលភស្តុតាង ដើម្បីធ្វើការកំណត់ថា តើសកម្មភាពទាំងនេះ អាចពង្រីកទៅអនុវត្តតាមកន្លែងផ្សេងទៀតបានដែរឬទេ។

បញ្ហាប្រឈមទាំងនេះ រំលេចឱ្យឃើញអំពីបញ្ហាដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ដូចជា បញ្ហាកង្វះធនធានមនុស្ស និងធនធានដទៃទៀត ការវិនិយោគរបស់រដ្ឋាភិបាល ការពង្រឹង ការអនុវត្តច្បាប់ និងកត្តាសង្គមផ្សេងទៀត ដូចជាការធ្វើចំណាកស្រុក ជាដើម។

អង្គការជាច្រើន បានរាយការណ៍ថា ការធ្វើចំណាកស្រុកនៅតែជាបញ្ហាប្រឈមមួយ ដែលជាឧបសគ្គសម្រាប់ការអនុវត្តអន្តរាគមន៍ជាច្រើន។ បញ្ហាប្រឈមនេះ នាំឱ្យមានបញ្ហាជាច្រើនផ្សេងទៀត ដូចជា ការរក្សាធនធានចេះដឹង ឬសមត្ថភាពក្នុងស្រុក និងការបង្កឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម និងការផ្លាស់ប្តូរឥរិយាបថ ជាដើម។ ចំណាកស្រុក នាំឱ្យមានការផ្លាស់ប្តូរទម្លាប់របស់អ្នកផ្តល់ការថែទាំ ដោយសារតែឪពុកម្តាយរបស់ក្មេងភាគច្រើនបានធ្វើចំណាកស្រុក។

សមាជិកជាច្រើននៃសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ នៅកម្ពុជានេះ រំពឹងថា អន្តរាគមន៍របស់ខ្លួននឹងមានការផ្លាស់ប្តូរពីឆ្នាំ ២០១៧ ដល់ ២០១៨។ អង្គការជាច្រើន នឹងបញ្ចប់សកម្មភាពរបស់ខ្លួនមុន ចុងឆ្នាំ ២០១៧។ អង្គការមួយចំនួនបានបន្ទាបចំណុចដៅរបស់ខ្លួន ដើម្បីអាចអនុវត្តសកម្មភាពផ្លាស់ប្តូរឥរិយាបថ និងសង្គម តាមរយៈការប្រាស្រ័យទាក់ទង ដើម្បីផ្តោតឱ្យកាន់តែចំតម្រូវការរបស់បុគ្គល និងគ្រួសារ ជាជាងគ្រាន់តែរៀបចំកិច្ចប្រជុំបង្កើនការយល់ដឹងតាមសហគមន៍ ដែលធ្លាប់តែអនុវត្តកន្លងមក។

ដូចលើកឡើងខាងលើ ការវិភាគលើផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភបង្ហាញថា គេនៅមានឱកាសជំរុញឱ្យមានការចូលរួមពីក្រុមប្រឹក្សាឃុំ និងប្រើប្រាស់មូលនិធិឃុំ ដើម្បីពន្លឿនការអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅតាមសហគមន៍។ សក្តានុពលនេះ នៅមិនទាន់យកមកប្រើប្រាស់នៅឡើយ។ កម្មវិធីស្បៀងអាហារតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍ ក៏បានបង្ហាញផងដែរថា ការវិនិយោគនៅកម្រិតសហគមន៍ អាចធ្វើឱ្យមានការអនុវត្តសកម្មភាព ដែលគិតគូរពីអាហារូបត្ថម្ភកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ព្រមទាំងគណៈកម្មាធិការសាលារៀន និងក្រុមប្រឹក្សាឃុំផងដែរ។

## អាទិភាពទី ៣៖ លើកកម្ពស់ការគាំពារសង្គមទាក់ទិននឹងសន្តិសុខស្បៀង និងបង្កើនសមត្ថភាពរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដើម្បីទប់ទល់នឹងហានិភ័យ និងវិបត្តិ ដើម្បីបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់អាហាររបស់ពួកគេ

### ៣.១ ពង្រីកឧបករណ៍គាំពារសង្គមពាក់ព័ន្ធនឹងសន្តិសុខស្បៀង

នៅក្នុងរបាយការណ៍កន្លងមក មានការលើកឡើងថា មានការអនុវត្តសកម្មភាពជាច្រើន ដើម្បីពង្រីកការអនុវត្តឧបករណ៍គាំពារសង្គមពាក់ព័ន្ធនឹងសន្តិសុខស្បៀង។ឧបករណ៍ទាំងនេះភាគច្រើនពាក់ព័ន្ធជាមួយនឹងការផ្តល់ជំនួយសង្គម។ដូច្នេះការរៀបរាប់នៅក្នុងផ្នែកនេះអាចត្រួតគ្នាខ្លះជាមួយនឹងចំណុចស្តីពីកិច្ចគាំពារសង្គមដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ។ដៃគូអភិវឌ្ឍន៍បានសហការជាមួយនឹងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងអាជ្ញាធរមូលដ្ឋាន តាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសាកល្បងគម្រោងគាំទ្រការបង្កើតចំណូល។ ការអនុវត្តសាកល្បងនេះនឹងផ្តល់នូវមេរៀនមានប្រយោជន៍ជាច្រើន សម្រាប់រៀបចំសមាសភាគគាំទ្រការបង្កើតចំណូល ក្រោមសសរស្តម្ភជំនួយសង្គមនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានពង្រីកវិសាលភាពរបស់ខ្លួនគ្របដណ្តប់លើគ្រប់តំបន់ជនបទទាំងអស់។ ចាប់តាំងពីឆ្នាំ ២០១៥ មក ក្រសួងផែនការបានទទួលយកភាពជាម្ចាស់ទាំងស្រុងក្នុងការផ្តល់ថវិកាសម្រាប់អនុវត្តកម្មវិធីនេះនៅតំបន់ជនបទ។ បច្ចុប្បន្នេះ កំពុងមានការសាកល្បងយន្តការ

អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតំបន់ប្រជុំជន។ យន្តការកំណត់រកគ្រួសារក្រីក្រនៅតំបន់ប្រជុំជននេះបានបញ្ចូលការដាក់ពិន្ទុ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងភាពងាយរងគ្រោះមួយចំនួនដូចជា សុខភាព ពិការភាព អប់រំ និងការជាប់បំណុលជាដើម។ ពិន្ទុទាំងនេះ ក៏អាចនឹងត្រូវយកទៅប្រើប្រាស់ សម្រាប់តំបន់ជនបទផងដែរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តត្រួតពិនិត្យលើប្រព័ន្ធស្បៀងបម្រុងរបស់កម្ពុជា ដើម្បី គាំទ្រដល់ការឆ្លើយតបបន្ទាន់ ចំពោះគ្រោះមហន្តរាយធម្មជាតិ ឬព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡា ប្រកាសពីការប្តេជ្ញាចិត្តទទួលយកកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន មកអនុវត្តដោយខ្លួនឯងនៅឆ្នាំ ២០២១ រួចមក កម្មវិធីស្បៀងអាហារពិភពលោកបានគាំទ្រដល់ការពង្រីកគំរូនៃកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ (HGSF) នៅក្នុងសាលារៀនចំនួន ២ នៅក្នុងឆ្នាំ ២០១៤ ដល់សាលារៀនចំនួន ៨៤ នៅក្នុងឆ្នាំ ២០១៦។ គេរំពឹងថា រដ្ឋាភិបាលនឹងធ្វើការកែសម្រួល និងទទួលយកគំរូនេះ មកអនុវត្តដោយខ្លួនឯង នាពេលអនាគត។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើនថវិកាវិភាជន៍ប្រចាំឆ្នាំ សម្រាប់ផ្តល់អាហារូបករណ៍ដល់សិស្សបឋមសិក្សា ហើយបានទទួលយកកម្មវិធីស្រដៀងគ្នា ដែលកំពុងទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ មកអនុវត្តដោយខ្លួនឯងបណ្តើរៗ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ មក កម្មវិធីស្បៀងអាហារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្តកម្មវិធីស្បៀងហេដ្ឋារចនាសម្ព័ន្ធ (FFA)។ កម្មវិធីនេះមានគោលបំណងចំនួនពីរគឺ ផ្តល់ឱកាសការងារដល់គ្រួសារក្រីក្រ ដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង និងកាត់បន្ថយបញ្ហាខ្វះស្បៀងនៅក្នុងរយៈពេលខ្លីរបស់ពួកគេ នៅក្នុងរដូវខ្វះខាតស្បៀង ដែលកើតមានឡើងជារៀងរាល់ឆ្នាំ ហើយនៅក្នុងពេលជាមួយគ្នា ប្រជាពលរដ្ឋដែលទទួលបានស្បៀង ត្រូវចូលរួមបង្កើត ឬស្តារហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍។ ការកសាង ឬការស្តារហេដ្ឋារចនាសម្ព័ន្ធទាំងនេះក៏រួមចំណែកក្នុងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុផងដែរ។

ពីឆ្នាំ ២០១៤-២០១៦ តាមរយៈការសហការជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល កម្មវិធីហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងជីវភាពរស់នៅ (PALS) ដែលអនុវត្តដោយកម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ជំនួយស្បៀងដល់ប្រជាពលរដ្ឋចំនួន ២៩.១៥៨ គ្រួសារ ស្មើនឹង ១៤៥.៧៩០ នាក់ (ក្នុងនោះ ១១.១៣៣ គ្រួសារ ឬ ៥៥.៦៦៥ នាក់ ជាគ្រួសារក្រ១ និង២) ដែលក្នុងនោះ ប្រមាណជា ៥០% ជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

នៅក្នុងឆ្នាំ ២០១៥ ផែនការបម្រុងថ្នាក់ជាតិ សម្រាប់ទប់ទល់នឹងគ្រោះរាំងស្ងួត និងខ្យល់ព្យុះ ត្រូវបានរៀបចំឡើង គ្របដណ្តប់លើវិស័យចំនួន៦(សន្តិសុខស្បៀង អាហារូបត្ថម្ភ សុខាភិបាល ទឹកស្អាត និងអនាម័យ លំនៅដ្ឋាន អប់រំ និងគាំពារសង្គម)។ ទោះជាយ៉ាងណាក៏ដោយ ផែនការនេះ នៅមិនទាន់ត្រូវបានផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឡើយ។ វេទិកាឆ្លើយតបមនុស្សធម៌ បានធ្វើការកែសម្រួលផែនការព្រាងនេះ ដើម្បីរៀបចំនូវផែនការបម្រុងអន្តរស្ថាប័ន សម្រាប់គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងគ្រោះទឹកជំនន់ ដោយបានកែសម្រួលវិស័យទាំង ៦ ក្នុងផែនការបម្រុងថ្នាក់ជាតិនេះ ឱ្យស្របតាមតួនាទីភារកិច្ចរបស់ខ្លួន។ ផែនការបម្រុងអន្តរស្ថាប័ន ដែលបានបញ្ចូលសន្តិសុខស្បៀងអាហារូបត្ថម្ភ និងវិស័យសាច់ប្រាក់នេះ ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងមហន្តរាយខេត្ត ដោយមានការគាំទ្រពីដៃគូ បានធ្វើបច្ចុប្បន្នភាពផែនការត្រៀមបង្ការ និងឆ្លើយតបចំពោះស្ថានភាពអាសន្នរបស់ខ្លួន។ ការលើកកម្ពស់កិច្ចគាំពារសង្គមសម្រាប់វិស័យក្រៅប្រព័ន្ធ ជាពិសេស សម្រាប់ស្ត្រី ភាគច្រើនគឺជាការងារដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយចំនួន។ គម្រោងនៅថ្នាក់ជាតិ នៅពុំទាន់ពង្រីកវិសាលភាពរបស់ខ្លួនលើវិស័យនេះនៅឡើយទេ។

នៅក្នុងឆ្នាំ ២០១៦ មានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានធ្វើការងារមួយចំនួនដើម្បីស្វែងពីទស្សនទានស្តីពីសិទ្ធិទទួលបានអាហារនៅក្នុងបរិបទរបស់ប្រទេសកម្ពុជា។

## ៣.២ ធ្វើឱ្យប្រសើរឡើងនូវការត្រៀមលក្ខណៈទប់ទល់ និងកាត់បន្ថយគ្រោះមហន្តរាយ ព្រមទាំងលើកកម្ពស់ភាពធន់ទ្រាំរបស់គ្រួសារ ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

ការអង្កេតលើភាពធន់ទ្រាំរបស់គ្រួសារទូទាំងប្រទេស ដែលធ្វើឡើងបន្ទាប់ពីរដូវប្រាំងឆ្នាំ ២០១៦ បានបញ្ចូលនូវសូចនាករសុខភាពសំខាន់ៗជាច្រើន ដែលជួយបង្កើនការយល់ដឹង និងឆ្លើយតបចំពោះភាពងាយរងគ្រោះ ដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ការសិក្សានេះ ត្រូវបានពង្រីកបន្ថែមទៀត ដើម្បីដឹងឱ្យកាន់តែច្បាស់ពីភាពធន់ទ្រាំរបស់គ្រួសារ។

នៅថ្នាក់ជាតិ ព្រឹត្តិការណ៍ CamREx ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដោយវេទិកាឆ្លើយតបមនុស្សធម៌ សហការជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ហើយកាលពីឆ្នាំ ២០១៦ មានការធ្វើលំហាត់សមយុទ្ធនៅថ្នាក់ក្រោមជាតិនៅក្នុងខេត្តចំនួនពីរ គឺខេត្តកំពង់ធំ និងខេត្តបាត់ដំបង។

ក្រសួងធនធានទឹក និងឧតុនិយម បន្តសម្រេចបានវឌ្ឍនភាពនៅក្នុងការថែទាំ ស្តារឡើងវិញ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងអភិវឌ្ឍមូលធនសង្គម សម្រាប់គាំទ្រដល់ការបន្តដំណើរការសកម្មភាពធារាសាស្ត្រនានា។ វឌ្ឍនភាពក្នុងការគ្រប់គ្រងធនធានទឹក ដែលសម្រេចបានដោយក្រសួងធនធានទឹក និងឧតុនិយម ក្នុងការបំពេញទៅតាមគោលដៅពង្រីកសមត្ថភាពប្រព័ន្ធធារាសាស្ត្រ គិតត្រឹមចុងឆ្នាំ ២០១៦ រួមមាន៖

- ពង្រីកសមត្ថភាពស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលស្រូវចំនួន ២៥៧.៩២៦ ហិកតា ឱ្យបានដល់ ៥៦,២៨% នៃផ្ទៃដីបង្កបង្កើនផលសរុបចំនួន ៣.០៩៧.៦៤៧ ហិកតា នៅក្នុងឆ្នាំ ២០១៦ (តួលេខបានពីក្រសួងកសិកម្ម)។
- ពង្រីកសមត្ថភាពស្រោចស្រប់ដំណាំបន្ថែមឱ្យបាន ៣.៣៩៨ ហិកតា។
- បានបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកចំនួន ៤៦។
- ការពារលំនៅដ្ឋាន និងដំណាំស្រូវរបស់ប្រជាពលរដ្ឋពីគ្រោះទឹកជំនន់លើផ្ទៃដី៥២៦ហិកតាបន្ថែមទៀត។
- ទប់ទឹកប្រៃមិនឱ្យហូរចូលទៅក្នុងផ្ទៃដីបង្កបង្កើនផលស្រូវនិងដំណាំរួមផ្សំ៩៤០ហិកតាបន្ថែមទៀត។
- បង្កើនសមត្ថភាពព្យាករណ៍ព្រឹត្តិការណ៍អាកាសធាតុ ដើម្បីផ្តល់ព័ត៌មានឱ្យប្រជាពលរដ្ឋដឹងអំពីករណីមានព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងស្ថានភាពជលសាស្ត្រធ្ងន់ធ្ងរ។

ឧបសគ្គមួយចំនួន ដែលរារាំងក្រសួងធនធានទឹក និងឧតុនិយម មិនឱ្យសម្រេចបានគោលដៅដែលត្រូវបានដាក់ចេញក្រោមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមមាន ការចំណាយខ្ពស់លើហេដ្ឋារចនាសម្ព័ន្ធដែលធន់ទ្រាំនឹងអាកាសធាតុ ភាពចាំបាច់ក្នុងការគ្រប់គ្រងធនធានទឹកជាលក្ខណៈអន្តរវិស័យនិងការគ្រប់គ្រងអាងទន្លេដើម្បីឆ្លើយតបទៅនឹងកំណើនសម្ពាធលើធនធានទឹក ថវិកាតិចតួចសម្រាប់ការថែទាំ ការស្តារឡើងវិញ និងការជុសជុលប្រព័ន្ធធារាសាស្ត្រ ភាពយឺតយ៉ាវក្នុងផ្តល់ថវិកា និងភាពមិនឆ្លើយតបគ្នារវាងអាទិភាពវិនិយោគ និងតម្រូវការជាក់ស្តែង។ ការចូលរួមរបស់កសិករនៅក្នុងការប្រើប្រាស់ និងការថែទាំប្រព័ន្ធធារាសាស្ត្រក៏នៅមានកម្រិតផងដែរ។

## ចំណុចខ្វះខាត និងបញ្ហាប្រឈម

បញ្ហាប្រឈមជាច្រើនត្រូវបានរកឃើញចេញពីការវិភាគលើវឌ្ឍនភាព និងការកំណត់ឧបសគ្គ ដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨។

បញ្ហាប្រឈមមួយនៅក្នុងបញ្ហាប្រឈមទាំងនេះ គឺការបង្កើនប្រសិទ្ធភាព និងវិសាលភាពនៃយុទ្ធសាស្ត្រនេះ តាមរយៈការធានាឱ្យមានការភ្ជាប់ទំនាក់ទំនងឱ្យកាន់តែប្រសើរជាមួយក្រសួងពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។ លំហូរព័ត៌មានតិចតួចរវាងស្ថាប័នទាំងនេះ បង្កធ្វើឱ្យប៉ះពាល់ដល់ការចូលរួមរបស់ស្ថាប័នទាំងនេះ ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិស្បៀង និងអាហារូបត្ថម្ភផងដែរ។ ពុំមានការបែងចែកការទទួលខុសត្រូវចំពោះសកម្មភាព និងលទ្ធផល ក៏មានផលប៉ះពាល់ដល់ការចូលរួមក្នុងការអនុវត្ត និងការរាយការណ៍ផងដែរ។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀ ង និងអាហារូបត្ថម្ភ ដាក់ចេញសកម្មភាពជាអាទិភាពច្រើនពេក និងមានបញ្ជីសូចនាករដ៏ច្រើន ដែលចាំបាច់ត្រូវតម្រឹមឱ្យស្របទៅតាមកម្មវិធីដទៃទៀត ដូចជា សូចនាករពិនិត្យតាមដានរួមគ្នា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលត្រូវបានធ្វើមូលដ្ឋាននីយកម្មជាដើម។

វាពិជាការសំខាន់ណាស់ ដែលចាំបាច់ត្រូវមានការវិនិយោគឱ្យបានគ្រប់គ្រាន់ ដើម្បីបន្តការអនុវត្តដំណើរការពិនិត្យតាមដាន ដូចជាការអង្កេតប្រជាសាស្ត្រ និ ងសុខភាពកម្ពុជាជាដើម។ បញ្ហាដែលពាក់ព័ន្ធជាមួយនឹងការផ្តល់ហិរញ្ញប្បទានដល់ការសិក្សាទាំងនេះ ចាំបាច់ត្រូវតែដោះស្រាយឡើងតាមរយៈកិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។

ដោយសារតែអាហារូបត្ថម្ភ និងសន្តិសុខស្បៀង គឺជាបញ្ហាដែលមានលក្ខណៈអន្តរវិស័យ បញ្ហាប្រឈមធំមួយទៀត គឺការកំណត់រកការវិនិយោគ ដែលអាចរួមចំណែកកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងលើកកម្ពស់សន្តិសុខស្បៀង លើកលែងតែការវិនិយោគសម្រាប់អន្តរាគមន៍ ដែលផ្តោតតែលើអាហារូបត្ថម្ភ ដូចជាអន្តរាគមន៍ដែលធ្វើឡើងដោយក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយផ្តោតលើអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាលជាដើម។ បញ្ហាប្រឈមមួយទៀត គឺការធានាយ៉ាងណាឱ្យកម្មវិធី និងគោលនយោបាយតាមវិស័យផ្តោតការយកចិត្តទុកដាក់ឱ្យបានច្បាស់លើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងធានាឱ្យមានការរាយការណ៍ពីការវិនិយោគផង និងលទ្ធផលដែលសម្រេចបានផង។

បើទោះបីជាមានការសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងការបង្កើនសន្តិសុខស្បៀងយ៉ាងណាក៏ដោយ បញ្ហាអាហារូបត្ថម្ភនៅតែបន្តកើតមាន ដែ លពិបាកនឹងធ្វើការដោះស្រាយ ជា ពិសេសគម្លាតសង្គមសេដ្ឋកិច្ច និងគម្លាតនៅតាមតំបន់ នៃសូចនាករសំខាន់ៗមួយចំនួន។ គ្រួសារនៅគ្រប់កម្រិតចំណូលទាំងអស់ ជាពិសេស គ្រួសារដែលស្ថិតនៅបញ្ចភាគទាប នៅខ្វះព័ត៌មាន និងការយល់ដឹងកម្រិតមូលដ្ឋានអំពីអាហារូបត្ថម្ភនៅឡើយ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងស្ថាប័នពាក់ព័ន្ធនៅពុំមានធនធានគ្រប់គ្រាន់សម្រាប់សម្របសម្រួលអនុវត្តនិងពិនិត្យតាមដានយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនិងយុទ្ធសាស្ត្រដទៃទៀត។ជាការសំខាន់ណាស់ដែលរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ត្រូវដាក់ចេញអាទិភាពវិនិយោគរួមគ្នា ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការវិនិយោគលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ទំនាក់ទំនងនៅថ្នាក់ក្រោមជាតិ និងការអនុវត្តកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ចាំបាច់ត្រូវតែលើកកម្ពស់បន្ថែមទៀត។ ចំណុចនេះ ទាមទារឱ្យមានការចែករំលែកព័ត៌មាន ការផ្តល់ព័ត៌មានសម្រាប់ជាការធ្វើសេចក្តីសម្រេចចិត្ត និងការកសាងសមត្ថភាពបន្ថែមនៅគ្រប់កម្រិតទាំងអស់។ ដើម្បីឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ បានបំពេញការទទួលខុសត្រូវរបស់ខ្លួនបាន ពួកគេត្រូវតែភ្ជាប់ទំនាក់ទំនងជាមួយនឹងយន្តការ

សម្របសម្រួលថ្នាក់ជាតិ ហើយអាជ្ញាធរជាតិ ចាំបាច់ត្រូវធ្វើការងារតាមរយៈទំនាក់ទំនងទាំងនេះ ដើម្បីមានឥទ្ធិពលលើការសម្របសម្រួល ក៏ដូចជាភាពប្រទាក់ក្រឡា កិច្ចពិគ្រោះយោបល់ និងការគាំទ្រផ្នែកកម្មវិធី និងគោលនយោបាយនានា។

ផលប៉ះពាល់និងភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុបង្កឱ្យមានបញ្ហាប្រឈមមួយនោះគឺវិបត្តិដែលអាចនាំឱ្យសហគមន៍ដែលរងផលប៉ះពាល់អាចជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង ក្នុងរយៈពេលណាមួយ។ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសដែលងាយរងគ្រោះជាពិសេសចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការតាមដានផលប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិតម្រូវឱ្យមានការបង្កើនសមត្ថភាពរដ្ឋបាលមូលដ្ឋាននិងនៅថ្នាក់ជាតិ និងត្រូវការវិនិយោគបន្ថែមទៅលើប្រព័ន្ធព័ត៌មាន និងការសម្របសម្រួល ដើម្បីការប្រមូល និងចែកព័ត៌មាន។

ការធ្វើចំណាកស្រុក និងការពង្រីកទីក្រុង មានឥទ្ធិពលយ៉ាងខ្លាំងលើសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ខណៈពេលដែលដំណើរការទាំងនេះរួមចំណែកពង្រឹងកំណើន សេដ្ឋកិច្ចវាក៏បង្កផលប៉ះពាល់លើស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ដែលអាចបង្កការរំខានដល់សេដ្ឋកិច្ចនៅកម្រិតគ្រួសារ។ វិស័យកសិកម្មជួបប្រទះនឹងបញ្ហាប្រឈមពិសេសមួយ នៅក្នុងអំឡុងដំណើរការនៃបំលាស់ប្តូរស្ថានភាពសង្គមសេដ្ឋកិច្ច ដោយសារវិស័យនេះមានការទទួលខុសត្រូវទ្វេរទៅលើ ការធានាសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករខ្នាតតូច និងការធ្វើទំនើបកម្ម និងការរួមភាគទានចំពោះកំណើនសេដ្ឋកិច្ច។ ការបង្កើនការទទួលបានស្បៀង និងការប្រើប្រាស់ស្បៀង ក៏ជួបនឹងបញ្ហាប្រឈមផងដែរ។ ចំណែកការវិនិយោគធនធានទៀតសោត ក៏ពុំទាន់មានតុល្យភាពនៅឡើយ ដោយមានការផ្តោតខ្លាំងពេកលើផ្នែកផលិតកម្ម។ ចាំបាច់ត្រូវតែមានការបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនការធ្វើពិពិធកម្ម ការផលិត និងការប្រើប្រាស់ស្បៀង នឹងបង្កើនជំនួយសង្គម។ ការទទួលបានកម្មសិទ្ធិដី ប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រ នឹងសម្រាប់ប្រជាពលរដ្ឋដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង អាចជួយបង្កើនការទទួលបានស្បៀងរបស់ពួកគេ។ នេះគឺជាបញ្ហាប្រឈមដែលកាន់តែរីកធំទៅៗ ដោយសារដីមានកម្រិត ហើយចំនួនប្រជាជនចេះតែមានការកើនឡើង។ ការប្រកួតប្រជែងក៏កាន់តែមានច្រើនជាងមុន ហើយមានការទទួលស្គាល់ថា តម្រូវការដីសម្រាប់តាំងទីលំនៅមានច្រើនជាងដីដែលកសិករខ្នាតតូចភាគច្រើនកំពុងតែកាន់កាប់នាពេលបច្ចុប្បន្ននេះ។ កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការធ្វើប្រពលវប្បកម្ម និងផលិតភាពដីដែលមានស្រាប់ ប្រកបដោយនិរន្តរភាព គឺជាការងារមួយដែលលំបាក ដោយសារសម្ពាធមកលើការកាប់ឆ្ការព្រៃ និងការពង្រីកដីកសិកម្ម។

បន្ទុកទ្វេរដងនៃបញ្ហាអាហារូបត្ថម្ភ កាន់តែក្លាយទៅជាបញ្ហាប្រឈមប្រឈមធំទៅៗ ហើយស្ត្រីគឺជាអ្នកងាយរងគ្រោះពិសេស។ ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីបង្កើនការអប់រំអំពីអាហារូបត្ថម្ភ ក៏ដូចជា ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងផលិតផលជំនួស ការបំបៅកូនដោយទឹកដោះម្តាយ និងផលិតផលមីក្រូសារជាតិនានា។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការបន្តវិនិយោគដើម្បីធានានិរន្តរភាពសមិទ្ធផលដែលសម្រេចទាំងនេះផងដែរ ហើយក្នុងពេលជាមួយគ្នា បង្កើនការយកចិត្តទុកដាក់លើការបង្ការជំងឺឆ្លង។ ការគ្រប់គ្រងអាហារ និងផលិតភាពអាហារគឺជាក្តីបារម្ភដែលបន្តកើតមានឡើង ដែលបញ្ហានេះ មានទំនាក់ទំនងជាមួយនឹងការរៀបចំស្លាកទទួលស្គាល់ចំណីអាហារ ការធ្វើតេស្តគុណភាព និងការអប់រំដល់អ្នកប្រើប្រាស់។ ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជំរុញឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងកិច្ចការពាក់ព័ន្ធនឹងសុវត្ថិភាពអាហារ និងសន្តិសុខស្បៀង ក៏ដូចជា អាហារូបត្ថម្ភ។

ការបញ្ចូលមីក្រូសារជាតិ (រាប់បញ្ចូលទាំងការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល) ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ជាពិសេស ការគ្រប់គ្រងគុណភាព ការធានាគុណភាព នឹងការពង្រឹងការអនុវត្តច្បាប់។

ការពង្រីកផលិតកម្មនៅក្នុងស្រុក និងការរក្សាស្តង់ដារ និងការគ្រប់គ្រងលើផលិតផលនាំចូល សុទ្ធតែជាបញ្ហាចោទដូចគ្នា។

ការគ្របដណ្តប់នៃកម្មវិធីជំនួយ និងធានារ៉ាប់រងសង្គមនៅមានកម្រិតទាបនៅឡើយ ហើយពុំបានទូលំទូលាយដល់ ៦០% នៃប្រជាពលរដ្ឋឡើយ រួមទាំងជនពិការ និងចាស់ជរា ដែលភាគច្រើនអ្នកទាំងនេះ ស្ថិតនៅក្នុងវិស័យក្រៅប្រព័ន្ធ។ ការគ្រប់គ្រងគម្រោងផ្សេងៗគ្នា នៅមិនទាន់បានបង្កើត និងធ្វើសមាហរណកម្មបញ្ចូលគ្នាឱ្យបានគ្រប់គ្រាន់នៅឡើយ ដែលនាំឱ្យគម្រោងទាំងនេះត្រូវបាត់បង់ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពរបស់ខ្លួន។ ការសម្របសម្រួលនៅកម្រិតគោលនយោបាយ និងការពិនិត្យតាមដាន និងការវាយតម្លៃ ដើម្បីធានាឱ្យការអនុវត្តសកម្មភាពនៅក្នុងកម្រិតកម្មវិធីគម្រោងមានគណនេយ្យភាព និងតម្លាភាព ក៏នៅមានកម្រិតតិចតួចផងដែរ។

ការរៀបចំការផ្តល់ហិរញ្ញប្បទានសម្រាប់ ការអនុវត្ត យុទ្ធសាស្ត្រជាតិស្តីពី កិច្ចគាំពារសង្គម ទាមទារឱ្យមានការពិគ្រោះយោបល់រវាងតួអង្គពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ ឧទាហរណ៍ ស្ថាប័នដែលមានភារកិច្ចផ្តល់សេវាដល់ក្រុមដែលងាយរងគ្រោះ ដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ជាដើម និងពុំមានធនធានគ្រប់គ្រាន់ ដើម្បីសម្រេចទៅតាមគោលបំណងគោលនយោបាយរបស់ខ្លួននៅឡើយ។

ការកំណត់អត្តសញ្ញាណ និងការចុះឈ្មោះប្រជាពលរដ្ឋទូទៅ ការកំណត់អត្តសញ្ញាណជនក្រីក្រដែលងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជី នៅមិនទាន់មានភាពប្រទាក់ក្រឡាជាមួយនឹងគ្នានៅឡើយ។ ប្រការនេះនាំឱ្យមានការកំណត់អត្តសញ្ញាណ/ការចុះឈ្មោះត្រួតគ្នា និងការផ្តល់អត្ថប្រយោជន៍ស្ទួនគ្នាផងដែរ។

បញ្ហាប្រឈមទាំងនេះតម្រូវឱ្យមានថវិកាកាន់តែច្រើនជាងមុន ពីថវិការបស់រាជរដ្ឋាភិបាលកម្ពុជាផង និងជំនួយអភិវឌ្ឍន៍ និងការវិនិយោគពីវិស័យឯកជនផង។ បញ្ហាប្រឈមនេះគឺជាបញ្ហាប្រឈមដ៏ធំនាពេលអនាគត។ កង្វះខាតការអនុវត្ត ធនធាន និងការចូលរួមរបស់អាជ្ញាធរនៅថ្នាក់ក្រោមជាតិសុទ្ធតែជាកត្តាដែលកំហិតសមិទ្ធផលដែលអាចសម្រេចបាន។ យើងចាំបាច់ត្រូវតែបោះជំហានទៅមុខ រៀបចំផែនការសកម្មភាពដែលមានលក្ខណៈបរិយាប័ន្ន ផ្តោតលើគោលបំណងចំនួនតិចប៉ុន្តែជាក់លាក់ និងមានការបែងចែកការទទួលខុសត្រូវ និងការកំណត់ថវិកាឱ្យបានច្បាស់លាស់។

## អនុសាសន៍សំខាន់ៗ

### ១. គួរមានការផ្តោតការយកចិត្តទុកដាក់ឱ្យកាន់តែច្រើនជាងមុន លើការបង្កើនការទទួលបានស្បៀង និងការប្រើប្រាស់ស្បៀង។

កម្មវិធីសន្តិសុខស្បៀងនានាច្រើនផ្តោតការយកចិត្តទុកដាក់លើផលិតកម្មស្បៀង។ប៉ុន្តែសម្រាប់កម្ពុជា ផលិតកម្មមិនមែនជាបញ្ហាជាអាទិភាពផ្នែកសន្តិសុខស្បៀងទេ។ គួរផ្តោតការយកចិត្ត ទុកដាក់លើការទទួលបានស្បៀង និងការប្រើប្រាស់ស្បៀង និងគួរមាន ការពិនិត្យឡើងវិញលើគោលនយោបាយ ផែនការ និងកម្មវិធី ដើម្បីរៀបចំជាអនុសាសន៍ដែលមានការរួមបញ្ចូលអំពី ការទទួលបានស្បៀង និងការប្រើប្រាស់ស្បៀង ដូចជាការបង្កើនការទទួលបានដីសម្រាប់ក្រុមងាយរងគ្រោះ ការផ្សព្វផ្សាយពីកសិកម្ម ដែលគិតគូរពីអាហារូបត្ថម្ភ ការលើកកម្ពស់ជីវភាពរស់នៅ ការអប់រំអំពីអាហារូបត្ថម្ភ ជំនួយសង្គម ទឹកស្អាត និងអនាម័យ និងការថែទាំសុខភាព ដើម្បីកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងបញ្ហាអសន្តិសុខស្បៀង។

ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងផែនការ ដើម្បីឱ្យមានការឆ្លើយតបចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការទទួលបានស្បៀង។

### ២. បង្កើនការយល់ដឹងពីហេតុផលជាមូលដ្ឋាន និងហេតុផលដែលបង្កឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ

បន្តស្វែងរកការគាំទ្រ ដើម្បីឱ្យមានការប្រើប្រាស់អភិក្រម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហាររូបត្ថម្ភ (អភិក្រម ដែលក្តោបលើប្រព័ន្ធស្បៀង ប្រព័ន្ធថែទាំ និងប្រព័ន្ធសុខាភិបាល)។ ពិចារណាកែសម្រួលយុទ្ធសាស្ត្រជាតិ ដើម្បីធានាឱ្យមានការបង្កើនការយកចិត្តទុកដាក់ចំពោះសន្តិសុខអាហារូបត្ថម្ភ និងការប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ គួរមានការអនុវត្តសកម្មភាពនៅថ្នាក់ក្រោមជាតិ ដើម្បីធានាយ៉ាងណាឱ្យការកសាងសមត្ថភាព ការផ្តល់ព័ត៌មាន និងការវិនិយោគ អាចជម្រុញឱ្យមានការអនុវត្តបានសម្រេច ដោយមានការចូលរួមពីសំណាក់អ្នកតាក់តែងគោលនយោបាយ ថ្នាក់ដឹកនាំ អ្នកជំនាញលើទស្សនៈពាក់ព័ន្ធ អ្នកអប់រំ និងវិស័យឯកជន។

### ៣. ពង្រឹងក្របខ័ណ្ឌសម្រាប់គ្រប់គ្រងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ចំណុចនេះ តម្រូវឱ្យមានការវិនិយោគបន្ថែមទៀតលើការស្វែងរកមតិគាំទ្រ ការសម្របសម្រួលការពិនិត្យតាមដាន និងការវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងការកសាងសមត្ថភាព។ ចាំបាច់ត្រូវមានការពង្រឹងការភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងពាក់ព័ន្ធក៏ដូចជាទំនាក់ទំនងជាមួយថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមានការឯកភាពលើការទទួលខុសត្រូវ និងធានាឱ្យមានការសម្រេចបានលទ្ធផលដែលបានគ្រោងទុក។ គួរមានការផ្សារភ្ជាប់ទំនាក់ទំនងសកម្មភាពជាអាទិភាព និងសូចនាករនានា ជាមួយការបែងចែកទំនួលខុសត្រូវ មិនថារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ឬវិស័យឯកជនឡើយ។ សូចនាករដែលបានកំណត់ គួរត្រូវបានធ្វើសនិទានកម្ម និងសុខុដុមនីយកម្មជាមួយនឹងអាទិភាពដែលបានព្រមព្រៀង កម្មវិធីតាមវិស័យ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលត្រូវបានធ្វើមូលដ្ឋាននីយកម្មសម្រាប់កម្ពុជា។ ធានាឱ្យមាននូវសមត្ថភាពប្រមូលទិន្នន័យឱ្យបានទៀងទាត់ និងមានការឯកភាពជាមួយស្ថាប័នដែលទទួលខុសត្រូវអំពីការចែករំលែកទិន្នន័យ។ លើសពីនេះគេក៏ចាំបាច់ត្រូវវិនិយោគលើប្រព័ន្ធព័ត៌មានដ៏មានប្រសិទ្ធិភាព និងសមត្ថភាពប្រមូល វិភាគ រាយការណ៍ និងប្រើប្រាស់ទិន្នន័យ ជាយុទ្ធសាស្ត្រសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងផ្តល់ព័ត៌មានសម្រាប់ដាក់បញ្ចូលទៅក្នុងគោលនយោបាយ។

### ៤. ធ្វើការពិនិត្យគ្រប់ជ្រុងជ្រោយលើការអនុវត្ត និងបញ្ហាស្ថាប័ន ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩-២០២៣

### ៥. សង្គមស៊ីវិលគួរបន្តវិនិយោគលើអភិក្រមតាមសហគមន៍ គួបផ្សំជាមួយនឹងការវិនិយោគលើការអនុវត្តកម្មវិធីរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន

ឱកាសដើម្បីបន្តអនុវត្តអភិក្រមតាមសហគមន៍ រួមមាន៖

- ការទាញប្រយោជន៍ពីការងាររបស់សង្គមស៊ីវិល ដើម្បីសម្រេចគោលដៅរួម
- ការបង្កើនប្រសិទ្ធភាពការងារជាមួយក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងការវិនិយោគ ដោយបញ្ចូលអាហារូបត្ថម្ភ និងសន្តិសុខស្បៀង
- ការប្រើប្រាស់រចនាសម្ព័ន្ធអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ដើម្បីពិនិត្យតាមដានវឌ្ឍនភាពដែលសម្រេចបាន ឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបចំពោះបញ្ហាអសមធម៌យេនឌ័រ
- ការបង្កើតយន្តការសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ នៅថ្នាក់ក្រោមជាតិ ដើម្បីមានការសម្របសម្រួលការងាររបស់អង្គការមិនមែនរដ្ឋាភិបាល នៅកម្រិតសហគមន៍ឱ្យកាន់តែល្អប្រសើរជាងមុន។

## ៦. ពង្រឹងភាពប្រទាក់ក្រឡាគ្នាជាមួយសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងកិច្ចគាំពារសង្គម

កិច្ចគាំពារសង្គម គឺជាកត្តាដ៏សំខាន់មួយ ក្នុងការធានាឱ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការអនុម័តលើក្របខ័ណ្ឌគោលនយោបាយគាំពារសង្គម គឺជាឱកាសដើម្បីធានាឱ្យមានការពង្រឹងទៅលើជំនួយសង្គម តាមរយៈការវិនិយោគរបស់រដ្ឋាភិបាល ជាពិសេសសម្រាប់ការលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា (ផ្តោតលើរយៈពេល ១.០០០ ថ្ងៃដំបូង) និងដើម្បីកាត់បន្ថយភាពរងគ្រោះរបស់ប្រជាពលរដ្ឋដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង។ ជំនួយសង្គមគឺជាយន្តការដ៏សំខាន់សម្រាប់ផ្តោតការយកចិត្តទុកដាក់លើសមធម៌នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការសន្យាមិនទុកនរណាម្នាក់ចោល។

## ៧. រៀបចំផែនការឆ្លើយតបចំពោះបន្ទុកទ្វេរដងនៃបញ្ហាអាហារូបត្ថម្ភ (រួមទាំងបញ្ហាឡើងទម្ងន់ និងបញ្ហាធាត់ជ្រុល)

កង្វះអាហារូបត្ថម្ភ បន្តបង្កផលប៉ះពាល់មកលើសង្គម និងសេដ្ឋកិច្ចទាំងមូល ហើយកម្រិតនៃបញ្ហាកង្វះអាហារូបត្ថម្ភនេះ នៅបន្តជាក្តីបារម្ភសម្រាប់កម្ពុជា។ ក្នុងពេលជាមួយគ្នា ការលើសអាហារូបត្ថម្ភ ដែលនាំឱ្យមានបញ្ហាលើសទម្ងន់ និងបញ្ហាធាត់ជ្រុល ក៏ជាបញ្ហាប្រឈមដែលបន្តកើតមានឡើងផងដែរ ដែលនឹងនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងសេដ្ឋកិច្ច។ បញ្ហាទាំងពីរនេះ គឺជាបញ្ហាស្មុគស្មាញដែលចាំបាច់ត្រូវធ្វើការដោះស្រាយ ហើយមានមូលដ្ឋានរួមជាច្រើនសម្រាប់ឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ។ កត្តាចំនួនពីរគឺ ការមានគោលការណ៍អាហារូបត្ថម្ភល្អ និងការអនុវត្តឱ្យបានល្អ សុទ្ធតែមានសារៈសំខាន់ដូចគ្នាក្នុងការឆ្លើយតបទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភផង និងបញ្ហាលើសអាហារូបត្ថម្ភផង។ គេប្រាកដជាអាចស្វែងរកមូលដ្ឋានរួមមួយរវាង គោលការណ៍ និងការអនុវត្ត។ កត្តាចាំបាច់ជាបន្ទាន់គឺរដ្ឋាភិបាលគួររៀបចំផែនការសកម្មភាព ដើម្បីឆ្លើយតបចំពោះបញ្ហាអាហារូបត្ថម្ភទាំងពីរនេះព្រមគ្នា ។ ផែនការទាំងនេះគួរជំរុញឱ្យវិស័យឯកជនចូលរួមឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធនឹងការផលិត ការនាំចូល ការផ្សាយពាណិជ្ជកម្ម ការដាក់កំហិតនៃការលក់ ការរួមចំណែកក្នុងប្រព័ន្ធផ្សព្វផ្សាយ ការវិនិយោគ និងបញ្ហាដទៃទៀត។

## ៨. ប្រើប្រាស់ទឡ្ហីករណ៍សេដ្ឋកិច្ច និងកិច្ចពិគ្រោះយោបល់អន្តរវិស័យដើម្បីជំរុញឱ្យរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនបង្កើនការវិនិយោគ ដើម្បីផ្តល់ថវិកាសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

## ប្រភពព័ត៌មាន

ឯកសារបូកសរុបវឌ្ឍនភាពនេះត្រូវបានចងក្រងចេញពីព័ត៌មាន ដែលទទួលបានពីចម្លើយចំពោះការអង្កេតដែលបំពេញដោយក្រសួងនានាដែលមានការទទួលខុសត្រូវលើសកម្មភាពអាទិភាពដែលត្រូវបានដាក់ចេញក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០១៤-២០១៨ ដែលត្រូវបានបែងចែកភារកិច្ចដោយក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានក្រុមការងារបច្ចេកទេសស្តីពីវិស័យគាំពារសង្គមសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាប្រធាន។

ការបែងចែកការទទួលខុសត្រូវរៀបចំរបាយការណ៍ អំពីវឌ្ឍនភាពធៀបនឹងសកម្មភាពជាអាទិភាព ត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំរបស់វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧ ក្រោមអធិបតីភាពឯកឧត្តម វេជ្ជបណ្ឌិត ជា សំណាង អគ្គលេខាធិការគណៈកម្មាធិការភូមិមួយផលិតផលមួយ និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី និងមានការព្រមព្រៀងគ្នាដូចខាងក្រោម៖

គោលបំណងទី ១៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង

- លើកកម្ពស់ពិពិធកម្ម និងសមាហរណកម្មទីផ្សារនៃការធ្វើកសិកម្មរបស់កសិករខ្នាតតូច – ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង FAO
- លើកកម្ពស់ការបែងចែកដី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជូនគ្រួសារក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង – ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង – ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង FAO
- លើកកម្ពស់ឱកាសការងារ និងឱកាសទទួលបានប្រាក់ចំណូលសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង – ក្រសួងផ្សេងៗ និង ILO

គោលបំណងទី ២៖ ការធ្វើឱ្យកាន់តែប្រសើរនូវការប្រើប្រាស់ និងការបឺតស្រូបស្បៀងអាហារ

- ពង្រីកសេវា និងការអប់រំអំពីអាហារូបត្ថម្ភ – ក្រសួងសុខាភិបាល និង UNICEF
- ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពក្នុងមូលដ្ឋាន និងការអនុវត្តអនាម័យ – ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យ
- ពង្រីកការបញ្ចូលមីក្រូសារធាតុទៅក្នុងចំណីអាហារ – ក្រសួងផែនការ និង UNICEF
- បង្កើនការមានស្បៀង និងការប្រើប្រាស់ស្បៀងឱ្យបានសមស្របនៅកម្រិតគ្រួសារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង FAO
- ការប្រើប្រាស់ឧបករណ៍គាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ – UNICEF និងក្រសួងសុខាភិបាល, ក្រសួងអភិវឌ្ឍន៍ជនបទ និង WFP
- អភិវឌ្ឍន៍ និងអនុវត្តកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ – ក្រសួងសុខាភិបាល និងបណ្តាញអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ

គោលបំណងទី ៣៖ បង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀង

- ពង្រីកសំណាញ់សុវត្ថិភាពសង្គមលើផ្នែកសន្តិសុខស្បៀង – ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និង WFP
- ធ្វើឱ្យប្រសើរឡើងនូវភាពបន្សាំរបស់គ្រួសារ នឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ – គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង WFP

ការអង្កេតជាមួយនឹងក្រសួងពាក់ព័ន្ធត្រូវបានប្រកាសធ្វើឡើងកាលពីថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០១៧ ក្នុងពិធីប្រកាសជាផ្លូវការចាប់ផ្តើមការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិលយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី។ ការឆ្លើយតបចំពោះការអង្កេតនេះត្រូវបានក្រសួងនានាដាក់ជូនក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសកម្ម និងជនបទ និងបានប្រមូលចងក្រងជារបាយការណ៍សង្ខេប ដែលត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់យោបល់បន្ថែម។ ដៃគូអភិវឌ្ឍន៍បានចូលរួមផ្តល់យោបល់លើឯកសារបូកសរុបវឌ្ឍនភាពដែលសម្រេចបាន ហើយយោបល់ទាំងនេះត្រូវបានបញ្ចូលទៅក្នុងឯកសារបូកសរុបវឌ្ឍនភាព ដែលសម្រេចបានក្នុងដំណើរការកែសម្រួលសេចក្តីព្រាងរបាយការណ៍នេះ។ ព័ត៌មានសង្ខេបត្រូវបានបង្ហាញក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានការប្រមូលយោបល់បន្ថែមទៀតពីអ្នកចូលរួមនៅក្នុងសិក្ខាសាលាទាំងនេះ។ ពង្រាងរបាយការណ៍នេះត្រូវបានដាក់ជូនសមាជិកនៃគណៈកម្មាធិការផ្តល់ប្រឹក្សាដែលមានឯកឧត្តម ងី ច័ន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធានដើម្បីពិនិត្យឡើងវិញមុននឹងរៀបចំបញ្ចប់។

ការទទួលខុសត្រូវលើការរៀបចំសេចក្តីព្រាង និងការផ្ទៀងផ្ទាត់ឯកសារព្រាងក្នុងអំឡុងពេលអង្កេត និងពិគ្រោះយោបល់ធ្វើឡើងក្រោមការទទួលខុសត្រូវរបស់លោក Iean Russell មន្ត្រីគោលនយោបាយជាន់ខ្ពស់នៃអង្គការស្បៀង និងកសិកម្មប្រចាំប្រទេសកម្ពុជា។ បន្ថែមពីលើការប្រមូល និងការចងក្រងចម្លើយចំពោះការអង្កេតទាំងនេះ និងយោបល់ដែលបានពីអ្នកពាក់ព័ន្ធនានា ឯកសារសំខាន់ៗមួយចំនួនត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំឯកសារបូកសរុបវឌ្ឍនភាពដែលសម្រេចបាន។

# បញ្ជីឯកសារយោង


## ឯកសាររបស់ស្ថាប័នរដ្ឋាភិបាល

Council for Agricultural and Rural Development (2014). National Strategy for Food Security and Nutrition 2014-2018.

Council for Agricultural and Rural Development (2016). National Action Plan for Zero Hunger Challenge in Cambodia 2016-2025.

Ministry of Agriculture, Forestry and Fisheries (2017). Annual Report and Direction 2017-2018 for Agriculture, Forestry and Fisheries 2016-2017.

Ministry of Health (2014). Fast Track Road Map for Improving Nutrition 2014-2020.

Ministry of Health (2016). National Budget for the Health Strategic Plan 2016-2020.

Ministry of Rural Development (2014) National Action Plan for Rural Water Supply, Sanitation and Hygiene 2014-2018.

NIS, Directorate General for Health, and ICF International (2015). Cambodia Demographic and Health Survey 2014.

Royal Government of Cambodia (2017). Mid Term Review 2016 on National Strategic Development Plan 2014-2018.

Royal Government of Cambodia (2017). National Social Protection Policy Framework (NSSPF) 2016 – 2025.

## ឯកសាររបស់ស្ថាប័ននានា

Humanitarian Response Forum (2017) Inter-Agency Contingency Plan for Flood, Storm, and Drought.

ទីស្ដីការគណៈរដ្ឋមន្ត្រី
#41 មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រលេខ៖ 2470 ទូរសារ/ទូរស័ព្ទ (+855) 23 426 824
អ៊ីម៉ែល៖ info@card.gov.kh គេហទំព័រ៖ www.card.gov.kh